លេខ ២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រកម្មវិធីកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឆ្នាំ២០១៦

# អារម្ភកថា



កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាផ្នែកមួយនៃកំណែទម្រង់ទាំងបួន នៃអភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ហើយត្រូវបានចាត់ទុកថាជាគន្លឹះសំខាន់នៃកំណែទម្រង់រដ្ឋបាលសាធារណៈ។ ក្នុងស្មារតីនេះ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នឹងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអោយកាន់តែប្រសើរឡើង ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ដែលជាធាតុចូលមួយដ៏សំខាន់សម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ និងការកាត់បន្ថយភាពក្រីក្រ។

ព្រឹត្តិបត្រ ដែលមិត្តអ្នកអានកំពុងកាន់នៅក្នុងដៃនេះ ជាសមិទ្ធផលថ្មីមួយទៀតដែលគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានបង្កើតឡើងក្រោមការណែនាំ និងគាំទ្រពីសំណាក់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ដើម្បីលើកកម្ពស់ការយល់ដឹងពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងពង្រីកវិសាលភាពនៃការផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបានទៅកាន់សាធារណជន និងផ្សព្វផ្សាយឱ្យកាន់តែប្រសើរ និងស៊ីជម្រៅជាងមុន។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានជំនឿយ៉ាងមុតមាំថា ព្រឹត្តបត្រនេះនឹងក្លាយជាមធ្យោបាយបន្ថែមទាំងចំណេះ និងការទទួលស្គាល់ពីការងារកែទម្រង់ ព្រមទាំងការបង្កើនការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយសម្រាប់មិត្តអ្នកអាន និងសាធារណៈជនគ្រប់ស្រទាប់វណ្ណៈ។ អគ្គលេខាធិការដ្ឋានសូមថ្លែងអំណរគុណចំពោះការណែនាំ និងគាំទ្រពីសំណាក់ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ដែលនេះជាការចូលរួមចំណែកមិនអាចខ្វះបានក្នុងការធ្វើឱ្យព្រឹត្តបត្រនេះអាចប្រសូតចេញបាន៕

# មាតិកា


១ | ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ........ ០១

២ | កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ០៣

៣ | ការវិភាជថវិកាឆ្នាំ២០១៦ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ០៦

៤ | ការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា÷ អត្ថប្រយោជន៍ បញ្ហាប្រឈម និងដំណោះស្រាយ ........ ១០

៥ | គោលបំណង និងការអនុវត្តថវិកាតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន សម្រាប់ថវិកាកម្មវិធី ........ ១៣

៦ | តើអ្វីទៅជាក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ........ ១៧

៧ | ការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ២១

៨ | ការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព ........ ២៤

៩ | វិធីសាស្ត្ររៀបចំផែនការសកម្មភាព ដំណាក់កាលទី៣ ........ ២៨

១០ | ការអនុវត្ត និងសារៈសំខាន់ នៃប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ (CMS) ........ ៣៤

១១ | ការគ្រប់គ្រងហានិភ័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ៣៥

# ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

ការទូទាត់ថវិកា ត្រូវធ្វើជារៀងរាល់ឆ្នាំ និងជាកម្មវត្ថុនៃច្បាប់។ សេចក្តីព្រាងច្បាប់ទូទាត់ថវិកាពិនិត្យ កត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលគណនីទោលរបស់រតនាគារជាតិ និងអាណាប័ណ្ណចំណាយ ដែលបានប្រព្រឹត្តនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។ សេចក្តីព្រាងច្បាប់នេះទុកជាមោឃៈ នូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឱ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង «គណនីលទ្ធផល» របស់រតនាគារជាតិ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកានីមួយៗ ដោយផ្អែកលើទិន្នន័យចំណូលចំណាយ ដែលរាយការណ៍ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈ និងផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃទិន្នន័យទាំងនេះ ដោយអាណាប័ក ទាំងសម្រាប់ថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មុននឹងដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យនិងសម្រេចដាក់ជូន សភាពិភាក្សានិងអនុម័ត។ របាយការណ៍នៃការអនុវត្តថវិកានេះ ចាំបាច់ត្រូវបង្ហាញនូវកិច្ចប្រតិបត្តិការនានា ដែលរួមមានដូចតទៅ÷

១. របាយការណ៍ចំណូល-ចំណាយ ថវិកាថ្នាក់ជាតិនៃកិច្ចប្រតិបត្តិការទូទៅ
២. របាយការណ៍កិច្ចប្រតិបត្តិការចំណូល-ចំណាយដែលអនុវត្តឆ្លងកាត់រតនាគារជាតិ
៣. របាយការណ៍កិច្ចប្រតិបត្តិការ ចំណូល-ចំណាយដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិ
៤. របាយការណ៍តុល្យភាពហិរញ្ញវត្ថុសាធារណៈ
៥. របាយការណ៍ចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី-ខេត្ត និង
៦. របាយការណ៍ចំណូល-ចំណាយ ថវិកាថ្នាក់ក្រោមជាតិរដ្ឋបាលក្រុង-ស្រុក។

ក្នុងកិច្ចដំណើរការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកានេះ, ការវាយតម្លៃលើការអនុវត្តថវិកា បង្ហាញឱ្យឃើញនូវបញ្ហាប្រឈមដែលត្រូវដោះស្រាយ ទិសដៅដែលត្រូវអនុវត្តបន្ត និងវិធានការដែលត្រូវប្រកាន់យកដើម្បីអនុវត្តថវិកានៃឆ្នាំបន្ទាប់។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ បានបង្ហាញថាក្នុងឆ្នាំ២០១៣ ចំណូលថវិកាអនុវត្តបានចំនួន ១៣.៣៦០.៥៣៤ លានរៀល រីឯចំណាយថវិកាអនុវត្តបានចំនួន ១៣.០៩០.៣៨៣,៣ លានរៀល ដែលនាំឱ្យលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៣ មានអតិរេក (Surplus) ចំនួន ២៧០.១៥០,៧ លានរៀល។ អតិរេកចំណូលចរន្ត និងចំណាយចរន្ត មានចំនួន១.៤២៣.៣៥៤,៧ លានរៀល រីឯឱនភាព (Deficit) ចំណូលមូលធន និងចំណាយមូលធន មានចំនួន ១.១៥៣.២០៤ លានរៀល។

លទ្ធផលជាវិជ្ជមាននេះ សបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលបានអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣ បានតាមអាទិភាពគោលនយោបាយសំខាន់ៗរបស់ខ្លួន ក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាល សម្រេចបាននូវសូចនាករសំខាន់ៗ នៃម៉ាក្រូសេដ្ឋកិច្ច ដូចជា កំណើនសេដ្ឋកិច្ចសម្រេចបាន ៧.៤% នៃផសស ធៀបនឹងការគ្រោងទុកប្រមាណ ៧% នៃផសស, ផសស សម្រាប់មនុស្សម្នាក់ៗ សម្រេចបាន ១០៤៣ ដុល្លារអាមេរិក, អតិផរណារក្សាបាន ៣% ធៀបនឹងការគ្រោងទុក គឺក្នុងរង្វង់ ៥%, អត្រាប្តូរប្រាក់ សម្រេចបានជាមធ្យម ៤.០២៥ រៀល ក្នុងមួយដុល្លារអាមេរិក ធៀបនឹងការគ្រោងទុក ៤.០៥០រៀល ក្នុងមួយដុល្លារអាមេរិក និងការអនុវត្តចំណូលសរុបសម្រេចបាន ០,៦៨% នៃផសស ធៀបនឹងការគ្រោងទុក ០,៤៨% នៃផសស ដែលនាំឱ្យមានលទ្ធភាពសន្សំអតិរេកថវិកាបាន។

ផ្អែកលើមូលដ្ឋាននៃការសម្រេចបាននូវសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំពុងឈានមកដល់ដំណាក់កាលទី៣ នេះ រាជរដ្ឋាភិបាលកាន់តែមានសុទិដ្ឋិនិយមថា កម្ពុជាពិតជាបាននិងកំពុងដើរលើផ្លូវដ៏ត្រឹមត្រូវ ដើម្បីអាចក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ខាងមុខ ជាក់ជាមិនខាន៕



# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ នៃកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ហិរញ្ញវត្ថុសាធារណៈ ត្រូវបានត្រួតពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ កិច្ចប្រជុំត្រួតពិនិត្យតាមដានវឌ្ឍនភាពជាប្រចាំខែ គឺជាកិច្ចប្រជុំកម្រិតបច្ចេកទេសរវាងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង- ស្ថាប័ន និងអគ្គលេខាធិការដ្ឋានគណៈ- កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ- វត្ថុសាធារណៈ (អ. គ. ហ.) រីឯកិច្ចប្រជុំត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំត្រីមាស ត្រូវបានធ្វើឡើងក្នុងយន្តការការងារបី គឺ គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ. ហ. ស.) និងកិច្ចប្រជុំ គ. ហ. ស. ជាមួយដៃគូអភិវឌ្ឍន៍ (PFM Steering Committee and Development Partners)។

ដោយឡែក កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ដោយមានការចូលរួមពីមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងកម្រិតដឹកនាំ កម្រិតគ្រប់គ្រង និងកម្រិតបច្ចេកទេស នៅតាមគ្រប់ក្រសួង- ស្ថាប័នដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធផងដែរ សរុបប្រមាណជាង ៥០០នាក់។

កិច្ចប្រជុំប្រចាំឆ្នាំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យនិងពិភាក្សាលើគ្រប់ទិដ្ឋភាព និងឱ្យបានគ្រប់ជ្រុងជ្រោយ លើវឌ្ឍនភាព បញ្ហាប្រឈម និងសំណើដំណោះស្រាយផ្សេងៗ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស គឺការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមួយឆ្នាំ ធៀបនឹងគោលដៅសមិទ្ធកម្មដែលបានកំណត់។

ជាទូទៅ កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព្រឹត្តទៅក្នុងរយៈពេល ០២ ថ្ងៃពេញ ដោយមានការចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយក- រដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចតែងតែផ្តល់អនុសាសន៍ណែនាំតម្រង់ទិសដ៏ថ្លៃថ្លាដល់រដ្ឋមន្ត្រី ប្រធាន ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៅតាមក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល ក៏ដូចជាឱកាសសម្រាប់ថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍ដែលតែងតែផ្តល់កិច្ចសហការនិងការគាំទ្រហិរញ្ញវត្ថុនិងបច្ចេកទេស ដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីប្រជុំត្រូវបានចាប់ផ្តើមតាមរបៀបវារៈនីមួយៗ ដោយមានការធ្វើបទបង្ហាញនិងកិច្ចពិភាក្សាលើប្រធានបទសំខាន់ៗ ជាបន្តបន្ទាប់រហូតឈានដល់ការបូកសរុបលទ្ធផលពីតំណាងអគ្គលេខាធិការដ្ឋាន




អ. គ. ហ. ព្រមទាំងមតិបូកសរុប និងសុន្ទរកថាបិទរបស់ថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កិច្ចដំណើរការនៃកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងតែត្រូវបានរៀបចំជា ២ វគ្គ គឺវគ្គទី១ «**កិច្ច- ប្រជុំពិភាក្សារួម**» និង វគ្គទី២ «**កិច្ចប្រជុំពិភាក្សាតាមក្រុម**»។

កិច្ចប្រជុំពិភាក្សារួម គឺជាវេទិកាទូលំទូលាយដែលមានអ្នកចូលរួមជាសមាសភាព មកពីក្រសួង- ស្ថាប័នទាំងអស់ និងដំណើរការទៅដោយមានការធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗ រីឯការពិភាក្សា សួរ-ឆ្លើយ ត្រូវបានរៀបចំជាវេទិការួមគ្នារវាងវាគ្មិនជាម្ចាស់បទបង្ហាញនីមួយៗ ដោយមានការដឹកនាំនិងសម្របសម្រួលដោយរដ្ឋលេខាធិការមួយរូប នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែក កិច្ចប្រជុំពិភាក្សាតាមក្រុម គឺជាកិច្ចប្រជុំពិភាក្សាតាមក្រុមតូចៗ ចំនួន ៤ ឬ ៥ ក្រុម ក្រោមការដឹកនាំនិងសម្របសម្រួលរបស់រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មួយរូប និងមានការចូលរួមពីមន្ត្រីតំណាងនៃគ្រប់ក្រសួង- ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើប្រធានបទដាច់ដោយឡែកពីគ្នា។

ជាក់ស្តែង កាលពីថ្ងៃទី២១ និង២២ ខែមីនា ឆ្នាំ២០១៦ កន្លងទៅនេះ កិច្ចប្រជុំត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពប្រចាំឆ្នាំ២០១៥ ត្រូវបានរៀបចំទន្ទឹមនឹងពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី៣ « ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយក- រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងថ្ងៃទី១ ដែលជាកម្មវិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី៣ បានដំណើរការទៅដោយមានការធ្វើបទបង្ហាញអំពីផែនការសកម្មភាពរួមដំណាក់កាលទី៣, សារាចររាជរដ្ឋាភិបាលស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ

តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និងបទបង្ហាញស្ដីពីអន្តរសកម្មរវាងកម្មវិធីកែទម្រង់ទាំង ៣ គឺកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយមានការចូលរួមធ្វើបទបង្ហាញផ្ទាល់ពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណៈកម្មាធិការកែទម្រង់នីមួយៗ។ បន្ទាប់មក វាគ្មិនជាន់ខ្ពស់នីមួយៗត្រូវបានអញ្ជើញឱ្យចូលរួមពិភាក្សា សួរ-ឆ្លើយ ក្នុងវេទិកាពិភាក្សាដែលដឹកនាំដោយឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថ្ងៃទី២ គឺជាកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដំណើរការទៅដោយមានការធ្វើបទបង្ហាញអំពីវឌ្ឍនភាពសំខាន់ៗក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ដែលក្នុងនោះរួមមានរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៥ និងរបាយការណ៍វឌ្ឍនភាពនៃគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ បន្ទាប់មក វេទិកាពិភាក្សា សួរ-ឆ្លើយ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីតំណាង អ.គ.ហ., តំណាងអគ្គនាយកដ្ឋានថវិកា, តំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងតំណាងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMWG) ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បន្ទាប់ពីកិច្ចប្រជុំពិភាក្សារួម រយៈពេលមួយថ្ងៃកន្លះខាងលើនេះរួចមក, សមាសភាពពីគ្រប់ក្រសួងស្ថាប័ន និងអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលទៅតាមក្រុមពិភាក្សានីមួយៗ ដែលត្រូវបានរៀបចំនិងបែងចែកជា ៥ ក្រុម ទៅតាមផ្នែកទាំង ៥ នៃក្របខ័ណ្ឌផែនការសកម្មភាពដំណាក់កាលទី៣ ដែលរួមមាន ក្រុម «ពង្រឹងភាពជឿទុកចិត្តនៃថវិកា», ក្រុម «ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ», ក្រុម «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ», ក្រុម «ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់» និងក្រុម «ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព»។ ប្រធានបទនៃកិច្ចពិភាក្សាតាមក្រុមនីមួយៗ គឺ ការដាក់ទម្ងន់លើផ្នែកគោលបំណង និងចង្កោមសកម្មភាពនីមួយៗ សម្រាប់ការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លទ្ធផលនៃកិច្ចពិភាក្សានិងសំណើតាមក្រុមនីមួយៗ ត្រូវបានលើកយកមកបង្ហាញដោយក្រុមនីមួយៗ ជូនដល់កិច្ចប្រជុំទាំងមូល។

មុននឹងដល់កម្មវិធីបិទ តំណាងនៃ អ.គ.ហ. បានឡើងធ្វើការបូកសរុបអំពីលទ្ធផលនៃកិច្ចប្រជុំទាំង ២ ថ្ងៃ ទាំងក្នុងក្រុមរួមនិងក្រុមពិភាក្សាទាំង ៥ ដើម្បីជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៅតាមក្រសួង-ស្ថាប័ននីមួយៗ ពិនិត្យនិងពិចារណាសម្រាប់ការបោះជំហាននៅឆ្នាំខាងមុខនិងជំហានបន្ទាប់។

ជាទីបញ្ចប់ ពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់-កាលទី៣ និងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធា-រណៈ ត្រូវបានបិទបញ្ចប់ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយក-រដ្ឋមន្ត្រីប្រចាំការនិងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានគូសរំលេចអំពីវឌ្ឍនភាពនៃការកែទម្រង់និងការលើកទឹកចិត្តឱ្យបន្តដំណើរការកែទម្រង់ទៅមុខទៀត៕



# ការវិភាជថវិកាឆ្នាំ២០១៦ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅឆ្នាំ២០១៦នេះរាជរដ្ឋាភិបាលគ្រោងវិភាជថវិកាសរុបចំនួន ១.៣៣៤.៥២៥ លានរៀល មានសមាមាត្រ ៧,៣០% នៃចំណាយថវិការដ្ឋសរុប មានកំណើន ២១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ហើយស្មើនឹង ១,៦៧% នៃផ.ស.ស. ជូនរដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីកម្រិត គឺរដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុកខណ្ឌ, និងឃុំ-សង្កាត់ ដើម្បីរ៉ាប់រងលើ (១) ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការ សមាជិកក្រុមប្រឹក្សាកំពុងបំពេញមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២) ចំណាយសម្រាប់ប្រតិបត្តិការ រដ្ឋបាល និង (៣) ចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋានក្នុងគោលដៅពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។



**ថវិការដ្ឋបាលរាជធានី-ខេត្ត** ត្រូវបានរៀបចំដោយផ្អែកលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ មាត្រា៣៥ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានចែងថា ក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងក្រោយពីការវិភាជកញ្ចប់ថវិកាបឋមនៅសប្តាហ៍ទី១ ខែមិថុនា ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំគម្រោងថវិកាចំណូលចំណាយលម្អិត របស់ខ្លួនផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការបូកសរុបនិងរៀបចំកិច្ចប្រជុំចរចាថវិកា។

សម្រាប់ឆ្នាំ២០១៦ នេះ ចំណូលថវិការាជធានី ខេត្ត មានទិន្នន័យដូចខាងក្រោម÷

| ចំណូលរាជធានី-ខេត្ត | លានរៀល | កំណើនជា % ធៀបច្បាប់ឆ្នាំ២០១៥ | % ធៀប ផសស |
|---|---|---|---|
| ចំណូលសារពើពន្ធ | ៧៧៧ ៥០៤ | ២៣,០% | ០,៩៧% |
| ចំណូលមិនមែនសារពើពន្ធ | ៣១ ៣៩០ | ១០,៥% | ០,០៤% |
| ចំណូលឧបត្ថម្ភពីថ្នាក់ជាតិ | ១០៥ ៧៤១ | ១៣,៤% | ០,១៣% |
| សរុប | ៩១៤ ៦៣៥ | ២១,៣% | ១,១៤% |

ផ្អែកលើមូលដ្ឋាននៃចំណូលនេះ រដ្ឋបាលរាជធានី ខេត្ត បានរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០១៦ ដូចតទៅ÷

| ចំណូលរាជធានី-ខេត្ត | លានរៀល | កំណើនជា % ធៀបច្បាប់ឆ្នាំ២០១៥ | % ធៀប ផសស |
|---|---|---|---|
| ចំណាយចរន្ត | ៧៦១ ៧៣០ | ២២,៦% | ០,៩៥% |
| ចំណាយមូលធន | ១៥២ ៩០៥ | ១៥,១% | ០,១៩% |
| សរុប | ៩១៤ ៦៣៥ | ២១,៣% | ១,១៤% |

**ថវិការដ្ឋបាលក្រុង-ស្រុក** ត្រូវបានរៀបចំដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃមូលនិធិក្រុងស្រុក និងអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក។

ឆ្នាំ២០១៦ កញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក រួមមាន÷

| ចំណូលរាជធានី-ខេត្ត | លានរៀល | កំណើនជា % ធៀបច្បាប់ ឆ្នាំ២០១៥ | % ធៀបចំណូលចរន្តថវិកាថ្នាក់ជាតិ ឆ្នាំ២០១៥ | % ធៀប ផសស |
|---|---|---|---|---|
| ចំណូលឧបត្ថម្ភពីថ្នាក់ជាតិ (មូលនិធិក្រុងស្រុក) | ៩៩ ១៣២ | ២៧,៦% | ០.៩% | ០,១២% |
| ចំណូលពីការផ្តល់សេវារដ្ឋបាលក្រុងស្រុក | ១២ ៣៤៨ | ២៤២,៩% | | ០,០២% |
| សរុប | ១១១ ៤៨០ | ៣៧,១០% | | ០,១៤% |

ចំណូលពីការផ្តល់សេវារដ្ឋបាលក្រុងស្រុក មានការកើនឡើងខ្ពស់ ដោយសារតែការពង្រឹងយន្តការផ្តល់សេវារដ្ឋបាលច្រកចេញចូលតែមួយនៅតាមក្រុង ស្រុក។

គួរបញ្ជាក់ ថាការផ្ទេរថវិកាពីថ្នាក់ជាតិជូនរដ្ឋបាលក្រុង ស្រុកនីមួយៗ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យបីចំណុចគឺ÷

(១) ផ្តល់អាទិភាពលើប្រាក់បៀវត្ស មន្ត្រីរាជការ ស្មៀនឃុំ សង្កាត់ និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាក្រុង ស្រុក

(២) វិភាជមិនឱ្យលើសពី ២៤% នៃកញ្ចប់មូលនិធិសរុប ដក កញ្ចប់ បៀវត្សនិងប្រាក់ឧបត្ថម្ភ សម្រាប់ចំណាយដំណើរការរដ្ឋបាល និង

(៣) ថវិកាដែលនៅសល់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

**ថវិការដ្ឋបាលឃុំ-សង្កាត់** ត្រូវបានរៀបចំដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទដ្ឋានគតិយុត្តិជាធរមាន។

សម្រាប់ឆ្នាំ២០១៦ កញ្ចប់ថវិការបស់រដ្ឋបាលឃុំ- សង្កាត់ រួមមាន÷

| ចំណូលរាជធានី-ខេត្ត | លានរៀល | កំណើនជា % ធៀបច្បាប់ឆ្នាំ២០១៥ | % ធៀបចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៥ | % ធៀប ផសស |
| --- | --- | --- | --- | --- |
| ការឧបត្ថម្ភពីថ្នាក់ជាតិ | ៣០៨ ៤១០ | ១៣,៤% | ២,៨% | ០,៣៨% |
| ចំណូលផ្ទាល់ | | | | |
| សរុប | | | | |

ការបែងចែកកញ្ចប់ថវិកាឃុំ សង្កាត់ តាមមុខសញ្ញាចំណាយត្រូវផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងអនុក្រឹត្យ ស្តីពីមូលនិធិឃុំ សង្កាត់ ដែលបានកំណត់ថា÷

(១) ផ្តល់អាទិភាពលើប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់

(២) វិភាជមិនឱ្យលើសពី ១៥% នៃកញ្ចប់មូលនិធិ សរុប ដក កញ្ចប់ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា សម្រាប់ចំណាយរដ្ឋបាល និង

(៣) ថវិកាដែលនៅសល់គឺសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

សម្រាប់ឆ្នាំ២០១៦ នេះ ថវិកាដែលត្រូវបានបែងចែកសម្រាប់កិច្ចប្រតិបត្តិការរដ្ឋបាលមានចំនួនសរុប ១៦០.១៧៧ លាន រៀល និងសម្រាប់ការអភិវឌ្ឍមូលដ្ឋានមាន ចំនួនសរុប ១៤៨.២៣៣ លានរៀល។ បន្ថែមពីលើធនធានវិភាជខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រោងវិភាជថវិកាបន្ថែមចំនួន ៨.០០០ លានរៀលទៀត សម្រាប់ពង្រឹងការគ្រប់គ្រងបរិស្ថាន សំណល់រឹងរាវ តាមទីប្រជុំជននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុងទាំង២៦។ កញ្ចប់សេវាអនាម័យបរិស្ថាននេះ ត្រូវបានវិភាជជូនរដ្ឋបាលក្រុងគោលដៅនីមួយៗ ផ្អែកតាមរូបមន្តដែលធានាសមធម៌និងតម្លាភាព និងបានកំណត់ថា ៥០% ត្រូវបានបែងចែកក្នុងទំហំស្មើៗគ្នា និង៥០%ទៀតត្រូវបានបែងចែក ទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋនៃក្រុងគោលដៅនីមួយៗ៕

# ការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាៈ អត្ថប្រយោជន៍ បញ្ហាប្រឈម និងដំណោះស្រាយ

តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនាចុងឆ្នាំ២០០៤ និងអនុវត្តពេញលេញនាឆ្នាំ២០០៥ កម្ពុជាបានប្តេជ្ញាធ្វើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ខ្លួនឆ្ពោះទៅរកស្តង់ដារអន្តរជាតិ ដើម្បីធានាថា ថវិកាជាតិពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពប្រាកដមែន។ រហូតមកដល់ពេលនេះ កម្ពុជាបានសម្រេចជោគជ័យជាសារវន្តនូវ «ភាពជឿទុកចិត្តបាននៃថវិកា» ដែលជាគោលដៅនៃដំណាក់កាលទី១ នាឆ្នាំ២០០៨ ហើយនិងកំពុងឈានទៅសម្រេចបានគោលដៅនៃដំណាក់កាលទី២ នាចុងឆ្នាំ២០១៥ ក្នុង«ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ» តាមរយៈការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី, មាតិកាថវិកាថ្មី, កិច្ចប្រតិបត្តិការចំណាយថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) មុននឹងឈានទៅដាក់ឱ្យអនុវត្តជាផ្លូវការនូវដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ នាដើមឆ្នាំ២០១៦។ យុទ្ធសាស្ត្រគន្លឹះនៃដំណាក់កាលទី៣នេះ គឺការកែទម្រង់ប្រព័ន្ធថវិកា ដែលរួមមានផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកា។ ក្នុងនេះ ផែនការយុទ្ធសាស្ត្រថវិកា ជាឯកសារយ៉ាងសំខាន់ជាបុរេលក្ខខណ្ឌសម្រាប់ភាពជោគជ័យនៃដំណាក់-កាលទី៣នេះ។

ផែនការយុទ្ធសាស្ត្រថវិកា (BSP) ជាផែនការថវិការយៈពេលមធ្យម(៣ឆ្នាំរំកិល) ដោយឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរ ជំនាញរាជធានី-ខេត្ត, ការកសាងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដើម្បីអនុវត្ត, និងការកំណត់សូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងការអនុវត្ត។ ផែនការយុទ្ធសាស្ត្រថវិកា ជាឯកសារផ្លូវការ ដែលអនុម័តដោយគណៈ-រដ្ឋមន្ត្រី និងជាមូលដ្ឋានចាំបាច់សម្រាប់រៀបចំថវិកាប្រចាំឆ្នាំ និងសម្រាប់ការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មរបស់ស្ថាប័នរដ្ឋ ព្រោះក្នុងដំណាក់កាលទី៣នេះ ថវិកាជាតិនឹងត្រូវវិភាជទៅតាមគោលបំណងគោលនយោបាយ និងកម្មវិធីជាមួយសូចនាករ និងគោលដៅច្បាស់លាស់។

ផែនការយុទ្ធសាស្ត្រថវិការួមមាន ៦ ផ្នែក គឺ÷ ផ្នែកទី១- សេចក្តីផ្តើម, ផ្នែកទី២- ការកំណត់គោលបំណងគោលនយោបាយ (ត្រូវឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ), ផ្នែកទី៣- ការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព, ផ្នែកទី៤- ការកំណត់ សូចនាករ និងគោលដៅសូចនាករ, ផ្នែកទី៥- ការកំណត់ធនធាន, និងផ្នែកទី៦- សេចក្តីសន្និដ្ឋាន។

## ក. អត្ថប្រយោជន៍

ផែនការយុទ្ធសាស្ត្រថវិកា មានអត្ថប្រយោជន៍យ៉ាងសំខាន់ សម្រាប់កំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ព្រោះជាឯកសារមូលដ្ឋានសម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣) ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះ-អំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី និងយុទ្ធសាស្ត្រ អាទិភាព និង (៥) ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និងការវិភាជថវិកា។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រថវិកានឹងជួយតម្រង់និងជំរុញឱ្យការវិភាជថវិកាចំទិសដៅ ការវិភាជថវិកាបម្រើឱ្យសកម្មភាពអាទិភាព និងការវិភាជថវិកាមានភាពជាក់ស្តែង ដើម្បីសម្រេចរាល់ចំណាយរបស់ស្ថាប័នរដ្ឋឱ្យបម្រើទាំងស្រុង និងសម្រេចបាននូវគោលបំណងគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពតាមវិស័យ ឈានទៅសម្រេចបានគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ លើសពីនេះទៅទៀត ផែនការយុទ្ធសាស្ត្រថវិកាក៏បាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន និងរវាងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ឱ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ។

## ខ. កិច្ចប្រឈម

ការងារកែទម្រង់ ដើម្បីផ្លាស់ប្តូរទម្លាប់ការងារ តែងប៉ះពាល់ដល់កិច្ចប្រតិបត្តិការការងារ ការប្រើប្រាស់ និងគ្រប់គ្រងធនធានមនុស្ស និងរចនាសម្ព័ន្ធគ្រប់គ្រង និងចាត់តាំងស្ថាប័នដែលមានស្រាប់។ ឯក្នុងកម្រិតបច្ចេកទេសវិញ ចាប់ពីឆ្នាំ២០១៦ តទៅ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាទាមទារការកំណត់គោលបំណងគោលនយោបាយ កម្មវិធី/យុទ្ធសាស្ត្រអាទិភាព អនុកម្មវិធី ដែលឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគ្របដណ្តប់គ្រប់តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ។ មិនត្រឹមតែប៉ុណ្ណោះ ការកំណត់សូចនាករត្រូវតែមានភាពគ្រប់ជ្រុងជ្រោយ មានន័យគ្រប់គ្រាន់ និងងាយយល់ ភាពជឿទុកចិត្ត ភាពសាមញ្ញ ភាពត្រឹមត្រូវ ភាពផ្ទៀងផ្ទាត់ និងប្រសិទ្ធភាព ឯគោលដៅសូចនាករត្រូវតែមានភាពសមស្រប និងប្រាកដនិយម ដែលអាចអនុវត្ត និងសម្រេចបានគោលបំណងគោលនយោបាយដែលបានកំណត់។ ចំណែកការព្យាករណ៍ធនធាន និងការគណនាតម្រូវការចំណាយត្រូវមានភាពគ្រប់ជ្រុងជ្រោយ និងសុក្រឹត។ ទាំងនេះសុទ្ធតែទាមទារឱ្យមានការប្តេជ្ញាចិត្ត ភាពជាម្ចាស់ និងឆន្ទៈខ្ពស់ក្នុងការដឹកនាំ លើសពីតម្រូវការចំណេះជំនាញរបស់មន្ត្រីដែលចាំបាច់មិនអាចខ្វះបាន ដើម្បីអាចឱ្យប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលទាំងមូលអាចសម្រេចបាននូវគោលដៅនៃគណនេយ្យភាពហិរញ្ញវត្ថុ។

## គ. ដំណោះស្រាយ

ដើម្បីដោះស្រាយកិច្ចប្រឈមខាងលើ ចាំបាច់ត្រូវមានកិច្ចសហការប្រកបដោយភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងបុរេសកម្មពីគ្រប់តួអង្គទាំងអស់។ សាមីក្រសួង-ស្ថាប័ន ដែលកំពុងអនុវត្ត និងរួមទាំងក្រសួង-ស្ថាប័នដែលត្រៀមខ្លួនអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ត្រូវមានឆន្ទៈនយោបាយ និងបច្ចេកទេសខ្ពស់ មានការដឹកនាំ ការគ្រប់គ្រង និងការសម្របសម្រួលការងារកែទម្រង់ ប្រកបដោយភាពហ្មត់ចត់ ភាពម៉ឺងម៉ាត់ ភាពអំណត់ និងការព្យាយាមកម្រិតខ្ពស់។ ក្នុងន័យនេះ អគ្គលេខាធិការដ្ឋានដឹកនាំ



ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ដែលជាសេនាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស) នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការផ្លាស់ប្តូរនេះប្រកបដោយទិសដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ ស្របនឹងយន្តការគ្រប់គ្រងត្រួតពិនិត្យជាប្រចាំ និងត្រៀមខ្លួនផ្តល់ជាជំនួយក្នុងកម្រិតគោលនយោបាយ និងបច្ចេកទេសសំដៅសម្រេចឱ្យបានគោលដៅចុងក្រោយនៃការងារកែទម្រង់ គឺថវិកាផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម។ ក្រៅពីនេះ ការងារមួយចំនួនត្រូវតែធ្វើដោយមិន អាចរំលងបានរួមមាន ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងសិទ្ធិ អំណាច និងការទទួលខុសត្រូវនៅក្នុងក្រសួង-ស្ថាប័ន ឱ្យបានច្បាស់លាស់, ការដាក់ឱ្យអនុវត្តអង្គភាពថវិកា, ការពង្រឹងក្រុមការងារថវិការបស់សាមីក្រសួង- ស្ថាប័នដែលមានសមាស-ភាគមកពីនាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ ឬ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង, ការពង្រឹងគុណភាពនៃការកំណត់សូចនាករ និងគោលដៅសូចនាករនៃលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយដោយផ្អែកលើព័ត៌មានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ លម្អិត សុក្រឹត និងទាន់ពេលវេលា៕

# គោលបំណង និងការអនុវត្តថវិកា តាមនីតិវិធី រជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី

ការរៀបចំ និងការអនុវត្តថវិកានៅកម្ពុជា ត្រូវបានធ្វើឡើងមួយឆ្នាំម្តង ដោយគិតការិយបរិច្ឆេទពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ។ បន្ទាប់ពីកញ្ចប់ថវិកា (ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ) ត្រូវបានអនុម័តដោយសភារួច ដើម្បីអាចអនុវត្តចំណាយថវិកាបាន ក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការលទ្ធកម្ម និងរៀបចំបង្កើតរជ្ជទេយ្យបុរេប្រទាន។ អាចមានសំណួរថា ហេតុអ្វីចាំបាច់គួរបង្កើតរជ្ជទេយ្យបុរេប្រទាន? ជាក់ស្តែង ការអនុវត្តនីតិវិធីលទ្ធកម្មអាចត្រូវការពេលវេលា ដោយត្រូវឆ្លងកាត់ធានាចំណាយ ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម (ដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ ជាដើម) រហូតដល់មានការចុះកិច្ចសន្យា និងការប្រគល់ទទួលទំនិញ សំណង់ ឬសេវា ទើបអាចទូទាត់ថវិកាបាន ដូច្នេះដើម្បីធានាបាននូវភាពរលូនពីដើមឆ្នាំនៃដំណើរការរដ្ឋបាល ចំណាយមួយចំនួនគឺមិនអាចរង់ចាំការបោះផ្សាយអាណត្តិតាមនីតវិធីធម្មតាបានទេ ដូចជា ការទិញសម្ភារៈការិយាល័យតូចតាច (ក្រដាសរ៉ាម ប៊ិច...) ការទិញទឹកសុទ្ធ ការជួសជុលតូចតាច និងសេវាផ្សេងៗមួយចំនួនជាដើម ត្រូវបានអនុញ្ញាតឱ្យធ្វើការចំណាយជាមុនតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ដែលផ្តល់សាច់ប្រាក់ជូនមុនសម្រាប់ចំណាយ ហើយធ្វើការបោះផ្សាយអាណត្តិនិយ័តកម្មដើម្បីទូទាត់ជម្រះបញ្ជីតាមក្រោយ ដើម្បីបំពេញបន្ថែមសាច់ប្រាក់ឡើងវិញសម្រាប់ចំណាយបន្តបន្ទាប់ទៀត។ ដោយឡែកចាប់តាំងពីដើមឆ្នាំ២០១៥មក មានការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ នៅក្រសួងស្ថាប័នចំនួន ១០ ដូច្នេះនីតិវិធីរជ្ជទេយ្យបុរេប្រទាន ក៏មានការកែសម្រួលមួយចំនួនផងដែរ។ ដើម្បីដឹងច្បាស់ថាការអនុវត្តចំណាយថវិកាតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ជាពិសេសសម្រាប់ថវិកាកម្មវិធី មានឯកសារគតិយុត្តអ្វីខ្លះ? និងមាននីតិវិធីលម្អិតយ៉ាងណា? សូមបន្តការអានលម្អិត ដូចខាងក្រោម÷

### ១. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទាន

- ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- សារាចរណែនាំលេខ០១៨ សហវ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីកិច្ចបញ្ជីកាគណនេយ្យរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ០០៤ សហវ. ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី

### ២. គោលការណ៍ទូទៅនៃការអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទាន

រជ្ជទេយ្យបុរេប្រទានគឺជាចំណាយលើដំណើរការរដ្ឋបាល និងចំណាយដែលមានលក្ខណៈជាប្រចាំ ចាំបាច់ បន្ទាន់ និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ មុខសញ្ញាចំណាយតាមរជ្ជទេយ្យបុរេប្រទាន រួមមាន÷

- ចំណាយចាំបាច់ជាប្រចាំ សម្រាប់ការងាររដ្ឋបាល (សម្ភារៈ, ការជួសជុល...)
- ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់និងពិសេស
- ចំណាយសម្រាប់ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស
- ចំណាយសម្រាប់លាភការរបស់បុគ្គលិក
- ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា
- ចំណាយសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពនៃថវិកាកម្មវិធី។

នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដោយបានផ្តល់អាទិភាពនិងលទ្ធភាពងាយស្រួលដល់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ជាពិសេសក្រសួង-ស្ថាប័នថវិកាកម្មវិធី ក្នុងការអនុវត្តចំណាយដំណើរ-ការរដ្ឋបាល និងសកម្មភាព នៃថវិកាកម្មវិធី ដែលមានលក្ខណៈជាប្រចាំ ចាំបាច់ និងបន្ទាន់ បានរលូនឆាប់រហ័ស និងទាន់ពេលវេលា ដើម្បីសម្រេចបាននូវសមិទ្ធផលនិងសូចនាករ តាមគោលដៅនិងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ប្រកបដោយភាពទាន់ពេល គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់។

### ៣. ការបង្កើតរជ្ជទេយ្យបុរេប្រទាន និងការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

ដើម្បីធានាឱ្យមានការទទួលខុសត្រូវ និងគណ-នេយ្យភាពច្បាស់លាស់លើការអនុវត្តថវិកាទៅតាមសកម្មភាពការងារនិងសម្រេចបានលទ្ធផលការងារកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពទាំងទិដ្ឋភាពថវិកា និងទិដ្ឋភាពសេវាសាធារណៈ រដ្ឋមន្ត្រីប្រធានស្ថាប័ន ឬប្រធានអង្គភាពសាធារណៈប្រហាក់-ប្រហែលដែលជាដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ឬ ប្រធានអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាកម្មវិធីរបស់ខ្លួន អាចស្នើសុំបង្កើតរជ្ជទេយ្យបុរេ-ប្រទាន និងតែងតាំងរជ្ជទេយ្យករបុរេប្រទាន ដើម្បីអាចដំណើរការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានរបស់ក្រសួង-ស្ថាប័ន និងអង្គភាពរបស់ខ្លួន។

#### ក. ការបង្កើតរជ្ជទេយ្យបុរេប្រទាន

ដើម្បីបង្កើនប្រសិទ្ធិភាពនិងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានការអនុវត្តចំណាយថវិកាតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី ប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព, គណនេយ្យភាព, ការសន្សំសំចៃ និងឆ្លើយតបតាមតម្រូវការទាន់ពេលវេលាទៅតាមកម្មវិធី, អនុកម្មវិធី និងចង្កោមសកម្មភាព តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានត្រូវរៀបចំជា២ប្រភេទ÷ តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេ-ប្រទានសម្រាប់ថវិកាកម្មវិធីតាមចំណាត់ថ្នាក់កម្មវិធី។

#### ខ. ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

រជ្ជទេយ្យករបុរេប្រទានអាចមានរជ្ជទេយ្យករបុរេ-ប្រទានរងមួយចំនួនជាជំនួយការតាមការចាំបាច់។ រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទាន

រងត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើការចំណាយតាមរជ្ជទេយ្យបុរេប្រទានដើម្បីអាចទទួលបន្ទុកជំនួសគណនេយ្យករសាធារណៈក្នុងកិច្ចប្រតិបត្តិការទូទាត់ចំណាយតាមរជ្ជទេយ្យបុរេប្រទាន។ ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ត្រូវអនុលោមតាមប្រការ៩ និងប្រការ១០ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន ឬ ប្រធានអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ និងគណនេយ្យករសាធារណៈ ហើយត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ផ្នែករដ្ឋបាល ផ្នែកផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាស ចំពោះការរក្សាការពារមូលនិធិដែលខ្លួនទទួលបាន និងការរក្សាទុកដាក់លិខិតយុត្តិការ ព្រមទាំងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការរជ្ជទេយ្យបុរេប្រទាន។

## ៤. នីតិវិធីនៃការទូទាត់ចំណាយតាមរជ្ជទេយ្យបុរេប្រទាន

កិច្ចដំណើរការនៃចំណាយតាមរជ្ជទេយ្យបុរេប្រទានមាន ០៤ដំណាក់កាល÷(១)-រជ្ជទេយ្យករបុរេប្រទានដកប្រាក់រជ្ជទេយ្យបុរេប្រទានពីគណនេយ្យករសាធារណៈ(២)-ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន (៣)-រជ្ជទេយ្យករបុរេប្រទានរៀបចំលិខិតយុត្តិការដាក់ជូនអាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិ ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម និង (៤)-ទទួលបានទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ និងទទួលបានការឯកភាពទូទាត់ពីគណនេយ្យករសាធារណៈជាចំណាយថវិកាស្ថាពរ។

នារៀងរាល់ដើមឆ្នាំថវិកា រជ្ជទេយ្យករបុរេប្រទានអាចស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានស្មើ ឬ តិចជាងចំនួនទឹកប្រាក់នៃជុំបង្វិលនៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានក្នុងឆ្នាំអនុវត្តថវិកា ប៉ុន្តែក្នុងករណីការបង្កើតរជ្ជទេយ្យបុរេប្រទាននាដើមឆ្នាំថវិកាមានភាពយឺតយ៉ាវ រជ្ជទេយ្យករបុរេប្រទានអាចបើកប្រាក់រជ្ជទេយ្យបុរេប្រទានដំបូងស្មើនឹងចំនួនទឹកប្រាក់មួយជុំបង្វិលនៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានឆ្នាំមុន ឬ នៃសេចក្តីព្រាងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានក្នុងឆ្នាំអនុវត្តថវិកា។

ចំនួនទឹកប្រាក់សម្រាប់មួយប័ណ្ណចំណាយសម្រាប់ថវិកាកម្មវិធី ត្រូវបានកំណត់មិនលើស ៥ លានរៀល លើកលែងតែចំណាយពិសេសរបស់រាជរដ្ឋាភិបាល, ចំណាយលើប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស, ចំណាយរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា, និងចំណាយដែលមានរបបកំណត់ច្បាស់លាស់ដែលត្រូវទូទាត់តាមការចំណាយជាក់ស្តែង ដោយមិនកំណត់ចំនួនទឹកប្រាក់ក្នុងមួយប័ណ្ណចំណាយ។ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយ និងធានាឱ្យមានការទទួលខុសត្រូវច្បាស់លាស់មុននឹងធ្វើការចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន គឺត្រូវមានគោលការណ៍ចំណាយពីអាណាប័ក ឬ អ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក ហើយរាល់ប័ណ្ណចំណាយ ត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ, វិក្កយបត្រ និងសក្ខីបត្រចំណាយ ដែលរជ្ជទេយ្យករបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬ ពីអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។

ជាគោលការណ៍នៃការចំណាយតាមរជ្ជទេយ្យបុរេប្រទាន គឺត្រូវមានប្រាក់មុនក្នុងបេឡារជ្ជទេយ្យបុរេប្រទាន ប៉ុន្តែក្នុងករណីពុំទាន់មានប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានអាចយកវិក្កយបត្រ ឬ សក្ខីបត្រចំណាយដែលបានចុះកាលបរិច្ឆេទរយៈពេលយ៉ាងយូរ៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន មកធ្វើជាលិខិតយុត្តិការចំណាយដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ប៉ុន្តែប័ណ្ណចំណាយត្រូវចុះកាលបរិច្ឆេទ នៅក្រោយពេលបានបំពេញបេឡាសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន។

នាពេលដំណាច់ឆ្នាំថវិកា ក្នុងករណីមានប្រាក់រជ្ជទេយ្យបុរេប្រទាននៅសល់ រជ្ជទេយ្យករបុរេប្រទានត្រូវយកប្រាក់ដែលនៅសល់នោះ ទៅបង់ជូនគណនេយ្យករសាធារណៈវិញ ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី ហើយទន្ទឹមនោះ រជ្ជទេយ្យករបុរេប្រទានត្រូវខិតខំប្រមូលលិខិតយុត្តិការចំណាយជូនអាណាប័កដើម្បីបោះផ្សាយអាណត្តិនិយ័តកម្មបញ្ជូនមកអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំថវិកា ដើម្បីទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានឱ្យបានទាន់ក្នុងឆ្នាំថវិកា។

ជារួម ថ្វីត្បិតតែនីតិវិធីរជ្ជទេយ្យបុរេប្រទាន មានការសម្រួលដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធានាបាននូវភាពរលូននិងភាពទាន់ពេលវេលានៃកិច្ចដំណើរការរដ្ឋបាលរបស់ខ្លួន តាមរយៈការបើកផ្តល់សាច់ប្រាក់ជូនមុនសម្រាប់ការចំណាយ រួចទើបបោះផ្សាយអាណត្តិទូទាត់តាមក្រោយពិតមែន តែជាឯកសារគតិយុត្តគឺមានគ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយ ហើយជានីតិវិធីគឺមានចែងច្បាស់លាស់ល្អិតល្អន់ដែលអាចធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានរតនាគារជាតិជាសេនាធិការក៏បានបើកច្រក និងកំពុងលើកកម្ពស់ការអនុវត្តចំណាយថវិកាតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន តាមប្រព័ន្ធធនាគារផងដែរ។ ចុងក្រោយ រជ្ជទេយ្យបុរេប្រទានក៏ជាឧបករណ៍លើកទឹកចិត្តមួយដល់ក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឈានទៅអនុវត្តថវិកាកម្មវិធីពេញលេញ៕

# តើអ្វីទៅជាក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)?




រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងទិសដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ជាជំហានៗឆ្ពោះទៅរកស្តង់ដារអន្តរជាតិ នោះគឺការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្អែកលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ(២០១៣-២០២០) តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេលវែង គ្រប់ជ្រុងជ្រោយ និងអនុវត្ត យុទ្ធសាស្ត្រ៤ ជំហាន ឬ/និង ៤ដំណាក់កាល គឺ (១) ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា (២) ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤) ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម។ ជាក់ស្តែងភាពជឿទុកចិត្តបាននៃថវិកា ដែលជាគោលដៅចម្បងនៃដំណាក់កាលទី១ ត្រូវបានចាប់ផ្តើមដាក់ឱ្យអនុវត្តនៅចុងឆ្នាំ ២០០៤ និងត្រូវបានអនុវត្តយ៉ាងពេញលេញនៅឆ្នាំ២០០៥ ហើយត្រូវបានបញ្ចប់ដោយជោគជ័យជាមួយនឹងការប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី២ គណនេយ្យភាពហិរញ្ញវត្ថុ នៅចុងឆ្នាំ២០០៨ និងត្រូវបានអនុវត្តយ៉ាងពេញលេញនៅ ដើមឆ្នាំ២០០៩ ដោយគ្រោងបញ្ចប់ក្នុងឆ្នាំ ២០១៥ ទន្ទឹមនឹងការឈានទៅអនុវត្តដំណាក់កាលទី៣ នាដើមឆ្នាំ២០១៦ ខាងមុខនេះផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ជាសេនាធិការ ក្នុងការដឹកនាំអនុវត្ត និងគ្រប់គ្រងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ អគ្គលេខាធិការដ្ឋាន អ.គ.ហ. បាននឹងកំពុងធ្វើការវាយតម្លៃនូវកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) សម្រាប់ឆ្នាំ ២០១១,២០១២ និង២០១៣។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន អ.គ.ហ. ក៏នឹងរៀបចំជារបាយការណ៍ ដែលនឹងបញ្ចប់នៅត្រឹមឆ្នាំ ២០១៥ ខាងមុខនេះ។

ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) គឺជាឧបករណ៍ស្តង់ដារសម្រាប់វាយតម្លៃ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេស ដោយផ្តោតលើការចំណាយសាធារណៈ កិច្ចការលទ្ធកម្ម និងប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុ និង

ការអភិវឌ្ឍសមត្ថភាពសម្រាប់ការងារកែទម្រង់ ដើម្បីធានាឱ្យបាននូវ (១) វិន័យថវិកា (២) ប្រសិទ្ធភាពនៃការវិភាជធនធាន និង (៣) ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈដោយមាន៣១ សូចនាករសមិទ្ធកម្ម (២៨ + D1-D2-D3)។ កម្មវិធីចំណាយសាធារណៈ និង គណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ត្រូវបានប្រកាសឱ្យប្រើប្រាស់តាំងពីឆ្នាំ២០០១ ដែលបានបង្កើតនូវក្របខ័ណ្ឌនៃ ភាពជឿទុកចិត្ត និងភាពគ្រប់ជ្រុងជ្រោយសម្រាប់ការវាយតម្លៃពីមុខងាររបស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវបានយកទៅអនុវត្តនៅបណ្តាប្រទេសមួយចំនួនធំ ចាប់ពីឆ្នាំ២០០៥ ដែលមានកម្រិតចំណូលខុសគ្នា មុខងាររដ្ឋបាលខុសគ្នា និងភូមិសាស្ត្រតំបន់ផ្សេងៗគ្នា។ អស់រយៈពេលជាង ៩ ឆ្នាំកន្លងទៅនៃការអនុវត្តក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) គឺមិនមានអ្វីកែសម្រួល ឬ ផ្លាស់ប្តូរដែលគួរឱ្យកត់សម្គាល់ទេ វានៅតែត្រូវបានចាត់ទុកជាឧបករណ៍ចាំបាច់ និងសំខាន់សម្រាប់ពិនិត្យមើលទិដ្ឋភាពទូលំទូលាយនៃកម្មវិធីកែទម្រង់មកដល់ពេលបច្ចុប្បន្ន។ ដៃគូសហប្រតិបត្តិការរបស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ពុំមានទំនោរចង់កែសម្រួលនូវគោលបំណងដើមនៃក្របខ័ណ្ឌនេះទេ តែផ្ទុយទៅវិញ គឺមានឆន្ទៈចង់ធ្វើបច្ចុប្បន្នភាពរបស់វា ដើម្បីឱ្យឆ្លើយតបទៅនឹងការអភិវឌ្ឍនៅក្នុង១ ទសវត្សចុងក្រោយក៏ដូចជាពង្រឹងផ្នែកដែលទទួលស្គាល់ថានៅមានខ្វះចន្លោះ និងពង្រីកការគ្របដណ្តប់ទៅដល់ទិដ្ឋភាពថ្មីដូចជាយុទ្ធសាស្ត្រថវិកា (Fiscal Strategy) ការប្រើប្រាស់ប្រភពព័ត៌មានសម្រាប់អនុវត្តការវិនិយោគសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ។ ទោះជាយ៉ាងនេះក្តី គោលបំណងនៃការធ្វើបច្ចុប្បន្នភាព គឺដើម្បីពង្រីកភាពប្រទាក់ក្រឡានៃសូចនាកររបស់ PEFA ព្រមទាំងការរក្សាបាននូវភាពដែលអាចប្រៀបធៀបសម្រាប់រយៈពេលវែង និងអាចមានលទ្ធភាពពង្រីកបាន។ ដៃគូសហប្រតិបត្តិការរំពឹងថា ការអនុវត្តការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើមូលដ្ឋាននៃក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) នាពេលបច្ចុប្បន្នវានឹងផ្តល់បាននូវការកែលម្អគ្រឹះនៃប្រព័ន្ធតាមដានការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាសម្រាប់កិច្ចពិគ្រោះយោបល់ និងការកសាងកម្មវិធីកែទម្រង់អាទិភាពសម្រាប់ អនាគត និងពង្រីកបន្ថែមនូវភាពដែលអាចអនុវត្តបានសម្រាប់រដ្ឋាភិបាល និងអ្នកប្រើប្រាស់។

ពិតណាស់ ដើម្បីឱ្យធានាបាននូវលទ្ធផលជាក់ស្តែង និងកម្រិតខ្ពស់នៃការអនុវត្តដំណាក់កាលទាំង២ (ដំណាក់កាលទី១ និងទី២) ក៏ដូចជាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការបោះជំហានទៅអនុវត្តដំណាក់កាលបន្ទាប់ គឺដំណាក់កាលទី៣ (ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ) តាមរយៈការដាក់ឱ្យអនុវត្តផែនការសកម្មភាពរួមទី៣ (CAP3) ក្នុងនោះឧបករណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ត្រូវបានយកមកអនុវត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាដោយគិតត្រឹមឆ្នាំ (២០១១,២០១២ និង២០១៣) ជាលើកទី២ក្នុងឆ្នាំ២០១៥។ លើកទី១ ឧបករណ៍ក្របខ័ណ្ឌ PEPA ត្រូវបានយកមកប្រើប្រាស់ក្នុងការវាយតម្លៃឆ្នាំ២០០៩ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលត្រូវបានបោះពុម្ពផ្សព្វផ្សាយក្នុងឆ្នាំ ២០១០ ដោយពេលនោះ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺត្រូវបានយកប្រើប្រាស់ជាមូលដ្ឋាននៃការរៀបចំផែនការសកម្មភាពរួមទី២ (CAP2) និងបានរកឃើញនូវចំណុចខ្លាំងសំខាន់ៗនៅក្នុងដំណើរការរៀបចំថវិកាដ៏រស់រវើក ភាពប្រាកដប្រជានៃថវិកាក្នុងឆ្នាំ មានការកែលម្អ និងការពង្រីកជាបណ្តើរៗ នៃគណនីទោលរតនាគារ។ ជារួម ការប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) លើកនេះ គឺមានគោលដៅដើម្បីស្វែងរកឱ្យឃើញច្បាស់នូវកង្វះខាតនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាមូលដ្ឋានដ៏មុតស្រួចសម្រាប់ការរៀបចំផែនការសកម្មភាពរួមទី៣ (CAP3) គាំទ្រដល់ការអនុវត្តដំណាក់កាលទី៣ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦ នាពេលដ៏ខ្លីខាងមុខនេះ។



ការប្រើប្រាស់ឧបករណ៍ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ បានឱ្យរដ្ឋាភិបាលកម្ពុជាអាចវាយតម្លៃ និងស្វែងយល់កាន់តែស៊ីជម្រៅអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការងារដែលចាំបាច់ត្រូវកែលម្អ និងបន្តអនុវត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសបង្ហាញពីលទ្ធភាព និងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការធ្វើការប្រៀបធៀបជាមួយនឹងលទ្ធផលរបាយការណ៍ឆ្នាំ២០១០ ដែលបានធ្វើដោយអ្នកវាយតម្លៃឯករាជ្យ។ លទ្ធផលរបស់ចំណាយ សាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុបាននឹងកំពុងក្លាយជាមូលដ្ឋានសំខាន់ក្នុងការរៀបចំផែនការសកម្មភាពរួមទី៣ (CAP3) ក្នុងការសម្រេចបាននូវការអនុវត្តកម្មវិធីកែទម្រង់ ទាំងមូល។ ទន្ទឹមនឹងនេះ ចំណាយសាធារណៈ និង គណនេយ្យភាពហិរញ្ញវត្ថុបានជួយកំណត់យ៉ាងច្បាស់នូវស្ថានភាព ឬ ចំណុចខ្វះខាតរបស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលត្រូវការកែលម្អ និងពង្រឹងបន្ថែម ជាពិសេស គឺ អគ្គនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នមួយចំនួន។ មិនត្រឹមតែប៉ុណ្ណោះ លំហាត់នៃក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ពិតជាជួយពង្រឹងសមត្ថភាពដល់អគ្គលេខាធិការដ្ឋាន អ.គ.ហ. ក្នុងការរៀបចំទិសដៅ និងយុទ្ធសាស្ត្ររបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាងនេះទៀត ឆ្លងតាមរយៈបទពិសោធន៍នៃការរៀបចំ និងវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន កសហវ និងក្រសួងស្ថាប័ន គួរយកចិត្តទុកដាក់ពិនិត្យលើរបាយការណ៍ព្រាងចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានក្នុងការពង្រឹងការរៀបចំ ផែនការសកម្មភាពរួមអគ្គនាយកដ្ឋាន និងផែនការសកម្មភាពរួមក្រសួងស្ថាប័នរបស់ខ្លួនក្នុងគោលដៅ ដើម្បីឈានទៅសម្រេចឱ្យបាននូវមហិច្ឆិតានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល៕

# ការរៀបចំ
# ផែនការសកម្មភាពដំណាក់កាលទី៣ នៃកម្មវិធី
# កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) ដែលជាស្ថាប័នគន្លឹះក្នុងការសម្របសម្រួលការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសហការជាមួយគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២០ ដែលមានគោលដៅជាសារវ័ន្តគឺ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ដែលក្នុងនោះសកម្មភាពការងារជាអាទិភាពគឺការរៀបចំផែនការសកម្មភាពសម្រាប់៣ឆ្នាំដំបូង (២០១៦-២០១៨) ហើយនឹងរំកិលផែនការសកម្មភាពមួយឆ្នាំម្តងៗរហូតដល់ឆ្នាំ២០២០។

ដើម្បីបានជាមូលដ្ឋាននៃការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣នេះ អ.គ.ហ បានដាក់ចេញនូវសកម្មភាពការងារចម្បងមួយចំនួនគឺ (១) ការត្រួតពិនិត្យមើលឡើងវិញនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ និងដំណាក់កាលទី២ថ្មី (២០០៩-២០១៤) និង (២) ការវាយតម្លៃលើចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PEFA)។

លទ្ធផលនៃការត្រួតពិនិត្យឡើងវិញលើផ្នែកទាំង៤នៃដំណាក់កាលទី២ និងដំណាក់កាលទី២ថ្មី (២០០៩-២០១៤) បានបង្ហាញថា ទោះបីជាភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវ័ន្ត ប៉ុន្តែមិនទាន់បានបង្កើនទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននោះទេ។ ហើយលទ្ធផលនៃការត្រួតពិនិត្យឡើងវិញក៏បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបន្តកែលម្អ និងពង្រឹងការងារមួយចំនួនដូចជាការអនុវត្តផែនការលទ្ធកម្ម កម្មវិធីចំណាយប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រមូលចំណូល និងការគ្រប់គ្រងសាច់ប្រាក់ដើម្បីឆ្ពោះទៅធានាភាពជឿទុកចិត្តលើថវិកាប្រកបដោយស្ថិរភាព។ ម្យ៉ាងវិញទៀត ក្នុងគោលដៅបង្កើនគណនេយ្យភាពហិរញ្ញ-វត្ថុ សកម្មភាពការងារផ្តោតជាសំខាន់ទៅលើការកសាងនិងដាក់ឱ្យអនុវត្តប្លង់គណនីថ្មី មាតិកាថវិកាថ្មី អង្គភាពថវិកា ប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុនិងការកែលម្អថវិកា ព្រមទាំងការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏មិនទាន់បានសម្រេចបានតាមការគ្រោងទុកដែរ ដែលលទ្ធផលនៃការត្រួតពិនិត្យឡើងវិញបានវាយតម្លៃថាសម្រេចបានតែប្រមាណ៧០% ប៉ុណ្ណោះ។ លទ្ធផលនេះឆ្លុះបញ្ចាំងពីភាពចាំបាច់ដែលត្រូវបន្តកែលម្អនិងពង្រឹងជាពិសេសការងារដែលនៅសេស-សល់ត្រូវបន្តអនុវត្តនៅដំណាក់កាលទី៣។ ដោយឡែកសកម្មភាពការងារសម្រាប់ត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ រួមមានការធ្វើសមាហរណកម្មថវិកា ការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី គឺសម្រេចបានប្រមាណ៨៨%។

ដោយឡែកចំពោះការវាយតម្លៃលើចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ដែលជាឧបករណ៍ដ៏មានសារសំខាន់មួយសម្រាប់វាយតម្លៃលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាទាំងមូល ក៏បានរំលេចឱ្យឃើញពីភាពចាំបាច់ក្នុងការរៀបចំផែនការសកម្មភាពចាំបាច់មួយចំនួនសម្រាប់អនុវត្តដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ហើយដែលផែន-ការសកម្មភាពចាំបាច់ទាំងអស់នោះត្រូវបានកំណត់នៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៣។

ជាក្របខ័ណ្ឌរួម ផែនការសកម្មភាពរួមដំណាក់-កាលទី៣ មាន ៥ផ្នែក ២១គោលបំណង និង៦៧ចង្កោមសកម្មភាព។ ដោយផ្អែកលើក្របខ័ណ្ឌរួមនេះ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ព្រមទាំងគ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការសកម្មភាពលម្អិតរបស់ខ្លួន ដើម្បីគាំទ្រដល់ការសម្រេចបាននូវសូចនាករគោលដៅគន្លឹះនៃដំ-ណាក់កាលទី៣ដូចដែលបានសង្ខេបក្នុងតារាងខាងក្រោម÷

| ផ្នែក | សូចនាករគោលដៅគន្លឹះ |
|---|---|
| ផ្នែកទី១÷ ភាពជឿទុកចិត្តនៃថវិកា | ▸ ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី+/-៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ)<br>▸ ការគ្រប់គ្រងបំណុលត្រូវសងនិងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព |

| ផ្នែក | សូចនាករគោលដៅគន្លឹះ |
| --- | --- |
| ផ្នែកទី២÷<br>គណនេយ្យភាពហិរញ្ញវត្ថុ | • ប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្តត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពត្រឹមឆ្នាំ២០១៨ (ចំណាត់ថ្នាក់ថវិកា ប្លង់គណនី ការអនុវត្ត FMIS ដំណាក់កាលទី១ និងដំណាក់កាលទី២)<br>• ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព តម្លាភាព សុក្រឹតភាព និងទាន់ពេលវេលា |
| ផ្នែកទី៣÷<br>ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | • ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ដែលរួមមានក្របខ័ណ្ឌចំណូលរយៈពេលមធ្យមក្របខណ្ឌចំណាយរយៈពេលមធ្យម និងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម) ត្រូវបានរៀបចំនិងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យនិងអនុម័ត<br>• ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព<br>• ថវិកាកម្មវិធីនិងអង្គភាពថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព |
| ផ្នែកទី៤÷<br>ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ | • ក្របខ័ណ្ឌថវិកាក្របខ័ណ្ឌគណនេយ្យភាព និងក្របខ័ណ្ឌសវនកម្មដោយផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ |
| ផ្នែកទី៥÷<br>ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព | • ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ មានសមានគតិភាពជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |

# ការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានចក្ខុវិស័យនិងយុទ្ធសាស្ត្រដ៏ជាក់លាក់ ដើម្បីធានាចីរភាពនៃការគ្រប់-




គ្រងបំណុលសាធារណៈ។ ក្នុងទស្សនវិស័យនេះ ក្របខ័ណ្ឌគតិយុត្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈត្រូវបានកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ និងត្រូវបានកំណត់លម្អិតដោយអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។ ផ្អែកលើមូលដ្ឋានគតិយុត្តទាំងនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ដែលត្រូវបានអនុម័ត កាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១២ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ មានមូលដ្ឋានផ្អែកលើគោលការណ៍

គន្លឹះ ០៤ យ៉ាងគឺ៖

១. ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកានិងសេដ្ឋកិច្ចអាចទ្រាំទ្របាន
២. ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬ លក្ខខណ្ឌអនុគ្រោះខ្ពស់
៣. ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើននិងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង
៤. ត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព, គណនេយ្យភាព,ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត។

ផ្អែកលើគោលការណ៍ខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីថ្មីសម្រាប់ឆ្នាំ២០១១-២០១៨ ក្នុងរង្វង់ពី ៤០០ លាន ទៅ ៧០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ និងបានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៨ ចំណុចផ្សេងទៀតសំដៅធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។ ជាលទ្ធផល រាជរដ្ឋាភិបាលសម្រេចបានជាសមិទ្ធផលជាសារវន្ត ដូចតទៅ៖

១. គ្រប់គ្រងបាននូវទំហំនៃការខ្ចីមិនឱ្យលើសពីពិដានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ
២. បានសម្រិតសម្រាំងយកតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់
៣. បានប្រើប្រាស់ឥណទានសម្បទានចំគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលដោយក្នុងនោះប្រមាណ៨០% សម្រាប់ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រមាណ ២០% សម្រាប់ការវិនិយោគលើវិស័យអាទិភាពផ្សេងទៀត និង
៤. រក្សាបាននូវចីរភាពបំណុលសាធារណៈ និងការកម្រិតហានិភ័យបំណុលឱ្យនៅទាប ដែលលទ្ធផលនេះត្រូវបានវាយតម្លៃ និងទទួលស្គាល់ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ ជាក់ស្តែង ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលរបស់កម្ពុជា ដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ីបានកើនពី៤,០ ពិន្ទុ នៅឆ្នាំ២០១០ ទៅ៤,៥ ពិន្ទុ នៅឆ្នាំ២០១១ និង ៥,០ ពិន្ទុ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ ធៀបនឹងពិន្ទុអតិបរមា៦,០។

ទន្ទឹមនឹងសមិទ្ធផលខាងលើ បញ្ហាប្រឈមដ៏ស្រួចស្រាល់មួយចំនួន ក៏បាននិងកំពុងចោទមានឡើងផងដែរ ទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត ដែលមានជាអាទិ៍ ដូចតទៅ៖

១. ភាពរឹងស្អូតនៃហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយហេតុថាសេដ្ឋកិច្ចកម្ពុជាកំពុងតែអភិវឌ្ឍរីកចម្រើនធំធាត់ដោយទើបតែបានចាកចេញពីឋានៈប្រទេសមានចំណូលទាបទៅជាឋានៈប្រទេសមានចំណូលមធ្យមកម្រិតទាប
២. លទ្ធភាពនៃការធ្លាក់ចុះអតិរេកថវន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់ ក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដើម្បីឈានទៅសម្រេចគោលដៅឱ្យបានជាង ១លានរៀល ក្នុងមួយខែ នៅឆ្នាំ២០១៨
៣. ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពីការធានារបស់រដ្ឋលើគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) និង ពីវិស័យធនាគារនិងហិរញ្ញវត្ថុ និង
៤. ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

បញ្ហាប្រឈមខាងលើនេះ ត្រូវបានយកមកគិតគូរនិងដោះស្រាយ នៅក្នុងកិច្ចដំណើរការបច្ចុប្បន្នកម្មយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ នៅរៀងរាល់ ៥ ឆ្នាំម្តង តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ជាលទ្ធផលយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ ត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ដែលត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥។

ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈរយៈពេលវែង និងបន្ថយហានិភ័យនៃការគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតនៅក្នុងកម្រិតទាបបំផុត សំដៅចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពរយៈពេលវែង ព្រមទាំងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ យុទ្ធសាស្ត្របច្ចុប្បន្នកម្ម បានដាក់ចេញនូវវិធានការគោលនយោបាយ ០៩ ចំណុច ដូចតទៅ៖

១. កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ៦០០ លានអេសដេអ៊ែរ សម្រាប់ឆ្នាំ២០១៥ និងក្នុងរង្វង់ពី ៧០០ លាន ទៅ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៦-២០១៨ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា។ ជារួម សម្រាប់ឆ្នាំ២០១៥-២០១៨ រាជរដ្ឋាភិបាលនឹងមិនបោះផ្សាយមូលបត្ររដ្ឋ ឬសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យដែលជាឧបករណ៍បំណុលថ្មីទេ តែក៏នឹងអាចធ្វើការសាកល្បងប្រើប្រាស់ឧបករណ៍ថ្មីនេះនៅពេលណាមួយ សម្រាប់ជាការចាប់ផ្តើមនៃទីផ្សារបំណុល (មូលបត្ររដ្ឋ) និងអាចជាមូលដ្ឋានសម្រាប់ឱ្យមានការបោះផ្សាយមូលបត្រឯកជន។
២. បន្តប្រើប្រាស់ឥណទានសម្បទានសម្រាប់ហិរញ្ញប្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង។
៣. បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP)។
៤. បន្តទទួលយកតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។
៥. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ សំដៅសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យមក្នុងរង្វង់ ៧ ភាគរយ និងកំណើនចំណូលថវិកាជាតិក្នុងរង្វង់ជាមធ្យម ០,៥ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ។
៦. បន្តអនុវត្តគោលការណ៍មជ្ឈការ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ។

៧. បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀតសម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប។

៨. បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធជាពិសេសហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) និងពីវិស័យធនាគារ និងហិរញ្ញវត្ថុ។

៩. បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្នុងគោលដៅខាងលើនេះ ការពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ គឺជាវិធានការគោលនយោបាយអាទិភាពមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ក្រសួង- ស្ថាប័នពាក់ព័ន្ធដើម្បីបន្តជំរុញល្បឿននៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ហេតុនេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការមុតស្រួចបន្ថែមដូចខាងក្រោម÷

១. រៀបចំក្របខ័ណ្ឌគោលនយោបាយរួមសម្រាប់គ្រប់គ្រងចំណាយវិនិយោគសាធារណៈប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាដោយត្រូវគ្របដណ្តប់ទាំងគម្រោងវិនិយោគផ្ទាល់ដោយថវិកាជាតិ, គម្រោងវិនិយោគហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និង

២. បន្តពង្រឹងនីតិវិធីប្រតិបត្តិការ និងគោលការណ៍ណែនាំសម្រាប់គ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ សំដៅធានាបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និងគណនេយ្យភាពនៃចំណាយវិនិយោគសាធារណៈ។

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកលលោក, សេដ្ឋកិច្ចតំបន់, និងសេដ្ឋកិច្ចកម្ពុជា បាននិងកំពុងវិវឌ្ឍក្នុងចលនាការរស់រវើក ប្រទាក់ក្រឡាគ្នា និងមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមក រវាងវិស័យឯកជន និងវិស័យសាធារណៈ រាជរដ្ឋាភិបាលកម្ពុជានឹងពង្រីកវិសាលភាពនៃការគ្រប់គ្រងបំណុល ឱ្យគ្របដណ្តប់លើបំណុលរួមរបស់ជាតិទាំងមូល ដោយត្រូវបញ្ចូលទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង ដែលនេះគឺជាចក្ខុវិស័យសម្រាប់រយៈពេលមធ្យម និងវែងនៃការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា៕



# វិធីសាស្ត្ររៀបចំ ផែនការសកម្មភាព ដំណាក់កាលទី៣

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានការចូលរួមអនុវត្តពីក្រសួង ស្ថាប័ន នៃព្រះរាជាណាចក្រកម្ពុជាចំនួន ៤០ ដែលរួមមានទាំងក្រសួង-ស្ថាប័ននៃអង្គនីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នតុលាការមួយចំនួនផងដែរ ដែលក្រសួង ស្ថាប័នទីមួយៗនោះ ត្រូវរៀបចំនិងអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Ministerial Action Plan) អនុលោមតាមក្របខ័ណ្ឌផែនការសកម្មភាពរួម (Consolidated Action Plan-CAP) ដែលត្រូវបានដាក់ចេញដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដោយឡែក ក្នុងក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទាំង ១៥ ក្រោមឱវាទ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (General Departmental Action Plan) នេះផងដែរ។

ក្របខ័ណ្ឌផែនការសកម្មភាពរួម សម្រាប់ដំណាក់កាលនីមួយៗ ត្រូវបានចែកចេញជា ៣ កម្រិត គឺ កម្រិត ផ្នែក, កម្រិត គោលបំណង (កម្រិត ១ ខ្ទង់), និងកម្រិតចង្កោមសកម្មភាព (កម្រិត ២ ខ្ទង់) ដែលកំណត់ដោយ គ.ហ.ស., រីឯកម្រិតសកម្មភាព (កម្រិត ៣ ខ្ទង់) ដែលត្រូវរួមចំណែកសម្រេចចង្កោមសកម្មភាព គោលបំណង និងផ្នែកនីមួយៗនោះ ហើយកម្រិតសកម្មភាពនេះ ត្រូវកំណត់ដោយក្រសួង- ស្ថាប័ននីមួយៗ។

សម្រាប់ដំណាក់កាលទី៣ «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ» ដែលត្រូវអនុវត្តពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ ក្របខ័ណ្ឌផែនការសកម្មភាពរួម ទី៣ (Consolidated Action Plan 3) ត្រូវបានចែកចេញដូចតទៅ÷

- **៥ ផ្នែក គឺ÷**
  - ផ្នែកទី១ ÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា
  - ផ្នែកទី២ ÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ
  - ផ្នែកទី៣ ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
  - ផ្នែកទី៤ ÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់
  - ផ្នែកទី៥ ÷ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព។
- **មាន ២១ គោលបំណង**
- **មាន៦៧ ចង្កោមសកម្មភាព**

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង- ស្ថាប័ននីមួយៗ (ក.ហ.ស.) មានភារកិច្ចសម្របសម្រួលនិងប្រមូលសរុបផែនការសកម្មភាព ពីគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ រួចផ្ញើមក អ.គ.ហ. ដើម្បីពិនិត្យផ្តល់យោបល់ និងកែលម្អ។ ផែនការសកម្មភាព របស់ក្រសួង- ស្ថាប័ននីមួយៗត្រូវចុះហត្ថលេខាដាក់ឱ្យ

អនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ហ.ស. និងត្រូវផ្ញើជូនប្រធាន គ.ហ.ស. តាមកាលកំណត់។

ជាជំហានដំបូង, មន្ត្រីពាក់ព័ន្ធ ត្រូវបែងចែកឱ្យដាច់រវាងការងារប្រចាំថ្ងៃនិងការងារកែទម្រង់។ ការងារប្រចាំថ្ងៃគឺជាការងារដែលត្រូវបានកំណត់ក្នុងមុខងារនិងភារកិច្ចដែលត្រូវធ្វើឱ្យសម្រេចបាននូវលទ្ធផលដែលបានកំណត់ និងផ្ដល់ជូនស្របតាមគោលនយោបាយនិងកម្មវិធីរបស់ក្រសួង-ស្ថាប័ន។ រីឯការងារកែទម្រង់គឺជាសកម្មភាពការងារដែលត្រូវបានរកឃើញថាគួរធ្វើ ដើម្បីបង្កើនផលិតភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការងារប្រចាំថ្ងៃ។

រូបភាពទី១÷ សកម្មភាពកែទម្រង់ក្លាយទៅជាសកម្មភាពប្រចាំថ្ងៃ

បន្ទាប់មក ដើម្បីរៀបចំសកម្មភាពឱ្យបានគ្រប់ជ្រុងជ្រោយ គប្បីពិចារណាស្វែងរកចម្លើយចំពោះសំណួរសំខាន់ៗចំនួនបួន តាមលំដាប់លំដោយដូចតទៅ÷

១. តើក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនោះមានប្រព័ន្ធហើយឬនៅ?
២. តើមានក្របខ័ណ្ឌគតិយុត្តគ្រប់គ្រាន់ហើយឬនៅ សម្រាប់គ្រប់គ្រងបញ្ហាណាមួយនោះ?
៣. តើមានឧបករណ៍/យន្តការហើយ ឬនៅដើម្បីអនុវត្តប្រព័ន្ធឬក្របខ័ណ្ឌគតិយុត្តនោះ?
៤. តើក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ មានធនធានមនុស្សគ្រប់គ្រាន់ហើយឬនៅសម្រាប់អនុវត្តប្រព័ន្ធ ក្របខ័ណ្ឌ និងយន្តការនោះ?

សំណួរទាំងបួននេះ អាចជួយឱ្យក្រសួង-ស្ថាប័នរៀបចំផែនការសកម្មភាពឱ្យឆ្លើយតបកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាឧទាហរណ៍ សម្រាប់ដំណាក់កាលទី៣ «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ» ក្រសួង-ស្ថាប័ន ត្រូវពិនិត្យនិងពិចារណាថាតើរចនាសម្ព័ន្ធរបស់ខ្លួនឆ្លើយតបបានទៅនឹងការអនុវត្តថវិកាកម្មវិធី ឬ អង្គភាពថវិកាដែរឬទេ។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន ត្រូវកំណត់និងរៀបចំគោលបំណងគោលនយោបាយនិងកម្មវិធី ឱ្យមានភាពប្រទាក់ក្រឡាគ្នាជាមួយយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ភាពប្រទាក់ក្រឡាគ្នានៃរចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ននឹងជំរុញល្បឿននៃការអនុវត្តទាំងការងារកែទម្រង់ ទាំងការងារប្រចាំថ្ងៃ ឱ្យកាន់តែប្រសើរជាងមុន។

រូបភាពទី២÷ អន្តរសកម្មក្នុងក្រសួង-ស្ថាប័ន

រីឯការរៀបចំសរសេរបញ្ចូលសកម្មភាព និងសូចនាករលម្អិតកម្រិត ៣ ខ្ទង់ ទៅក្នុងក្របខ័ណ្ឌផែនការសកម្មភាពដំណាក់កាលទី៣ ត្រូវអនុវត្តតាមវិធីសាស្ត្រចំនួន ៤ គឺ÷

១. សកម្មភាព និងសូចនាករ ត្រូវមានភាពជាក់លាក់ (Specific)
២. សកម្មភាព និងសូចនាករ អាចវាស់វែងបាន (Measurable)
៣. សកម្មភាព និងសូចនាករ អាចសម្រេចបាន (Achievable)
៤. សកម្មភាព និងសូចនាករ ត្រូវមានសមានគតិភាព ជាមួយនឹងមុខងារ (Relevant)
៥. សកម្មភាព និងសូចនាករ ត្រូវមានពេលវេលាកំណត់ច្បាស់លាស់ (Time-bound)។

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ននីមួយៗ អាចស្នើសុំការណែនាំឬការចង្អុលបង្ហាញបន្ថែមពីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីអនុវត្តវិធីសាស្ត្រនេះ សំដៅសម្រេចជាផែនការសកម្មភាពប្រចាំក្រសួង-ស្ថាប័ននីមួយៗ។

អ. គ. ហ. អាចពិនិត្យលទ្ធភាពផ្ដល់ជំនួយបច្ចេកទេសសមស្របតាមសេចក្ដីត្រូវការ និងសមត្ថភាពជាក់ស្ដែងរបស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង-ស្ថាប័ននីមួយៗ តាមវិធីសាស្ត្រដូចខាងក្រោម ÷

- ការពិភាក្សាណែនាំដល់មន្ត្រីបង្គោលនៃក្រុមការងារ កហស
- ការពិនិត្យនិងពិភាក្សាកំណត់អំពីសេចក្ដីត្រូវការកែទម្រង់ប្រចាំក្រសួង- ស្ថាប័ននីមួយៗ ជាមួយក្រុមការងារ កហស
- ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងណែនាំជូនដល់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងក្រុម

រូបភាពទី១




រូបភាពទី២



ការងារ កហស នៅតាមក្រសួង ស្ថាប័ននីមួយៗ។

## តារាងរៀបចំផែនការសកម្មភាពដំណាក់កាលទី៣

កូឡោនដែលត្រូវបំពេញគឺមានចំនួន៦ គឺ៖

**១. កូឡោនទី១ (គោលបំណង និងចង្កោមសកម្មភាព)៖** គ្រប់គោលបំណង និងចង្កោមសកម្មភាពត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈហើយក្រសួង-ស្ថាប័នត្រូវរៀបចំផែនការសកម្មភាពសម្រាប់គាំទ្រនៃកម្រិតចង្កោមសកម្មភាព។ សកម្មភាព៖ ត្រូវលេខកូដជាបីខ្ទង់ជាលេខស្ទិតជាលេខកូដបង្ហាញសកម្មភាពរបស់ក្រសួង-ស្ថាប័ន។ ឧទាហរណ៍៖ ១១. ហៅថាមួយខ្ទង់(កម្រិតគោលបំណង), ១១.១. ហៅថាពីរខ្ទង់ (កម្រិតចង្កោមសកម្មភាព, ១១.១.១. ហៅថាបីខ្ទង់(កម្រិតសកម្មភាព) ហើយលេខបន្ទាប់ គឺជាលេខស្ទិត។

**២.កូឡោនទី២(ពេលវេលាកំណត់)៖** ក្រសួងស្ថាប័នត្រូវកំណត់ពេលសម្រាប់សកម្មភាពលម្អិតនីមួយៗដើម្បីងាយស្រួលក្នុងត្រួតពិនិត្យ និងតាមដានវាយតម្លៃ។ ឧទាហរណ៍៖ សកម្មភាពមួយចាប់ផ្ដើម ខែមករា ឆ្នាំ២០១៦ ដល់ខែធ្នូ ឆ្នាំ២០១៦។

**៣.កូឡោនទី៣ (ក្រសួង ស្ថាប័ន/អង្គភាព)៖** គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរៀបចំឈ្មោះរបស់អង្គភាពពាក់ព័ន្ធ។ ប៉ុន្តែសម្រាប់ផែនការសកម្មភាពលម្អិតរបស់ក្រសួង ស្ថាប័ន គឺត្រូវដាក់ឈ្មោះ អគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទរបស់ក្រសួងស្ថាប័ន ដែលទទួលបន្ទុកអនុវត្ត។

**៤.កូឡោនទី៤ (សូចនាករសមិទ្ធកម្មគន្លឹះ)៖** សូចនាករកម្រិតពីរខ្ទង់ និងកម្រិតមួយខ្ទង់ត្រូវបានរៀបចំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សម្រាប់កម្រិតបីខ្ទង់ ក្រសួង ស្ថាប័នត្រូវបំពេញឱ្យស្របទៅតាមផែនការសកម្មភាពនីមួយៗ និងផ្សារភ្ជាប់ទៅនឹងសេចក្ដីត្រូវការចាំបាច់នៃការកែទម្រង់របស់សាមីក្រសួង ស្ថាប័ននីមួយៗ។

**៥.កូឡោនទី៥ (គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ)៖** ក្រសួងស្ថាប័នត្រូវគូស(✓) សម្រាប់សូចនាករនីមួយៗ ដើម្បីបញ្ជាក់ និងបង្ហាញគោលដៅសមិទ្ធកម្មប្រចាំត្រីមាស។ ឧទាហរណ៍៖ ១១.១.១ ត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈដែលមានសូចនាករសមិទ្ធកម្មគន្លឹះពីរ គឺ៖

- ទី១៖ មានរបាយការណ៍អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំមាស
- ទី២៖ មានរបាយការណ៍វឌ្ឍនភាពអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំឆ្នាំ។

**៦. កូឡោនទី៦ (ប្រភពហិរញ្ញប្បទាន)៖** ក្រសួង-ស្ថាប័ន ត្រូវបំពេញប្រភពហិរញ្ញប្បទានដែលមាននៅគ្រប់សកម្មភាព ដែលនៅត្រង់ប្រភពត្រូវដាក់ឈ្មោះប្រភព (ឧទាហរណ៍៖ ធនាគារពិភពលោក) និងត្រូវដាក់ចំនួនទឹកប្រាក់សម្រាប់ការងារនេះផងដែរ។

ខាងក្រោមគឺជាឧទាហរណ៍គំរូសម្រាប់ការរៀបចំផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



| គោលបំណង/ចង្កោមសកម្មភាព (១) | ពេលវេលាត្រូវការ (ថ្ងៃ ខែ ឆ្នាំ) (២) | | ក្រសួង ស្ថាប័ន/អង្គភាព (៣) | សូចនាករសមិទ្ធកម្មគន្លឹះ (៤) | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ (៥) | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន (៦) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | | |
| | ចាប់ផ្ដើម | បញ្ចប់ | | | តម ១ | តម ២ | តម ៣ | តម ៤ | តម ១ | តម ២ | តម ៣ | តម ៤ | តម ១ | តម ២ | តម ៣ | តម ៤ | ប្រភព | សរុប |
| ផ្នែកទី ១៖ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា<br>○ ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី+/-៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ)<br>○ ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព | | | | | | | | | | | | | | | | | | |
| ចំណាំ៖ ផែនការសកម្មភាពក្នុងផ្នែកទី១នេះ គួរត្រូវបញ្ចប់ត្រឹមដំណាច់ឆ្នាំ២០១៦។ ក្នុងករណីដែលអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រសួង ស្ថាប័នយល់ថាត្រូវការពេលវេលាវេលាបន្ថែមសម្រាប់អនុវត្តបន្ត ត្រូវកំណត់ពេលវេលា និងផែនការសកម្មភាពឱ្យបានច្បាស់ថានឹងបញ្ចប់នៅពេលណា និងត្រូវបញ្ជាក់ថាមូលហេតុអ្វីដែលមិនអាចបញ្ចប់បានត្រឹមដំណាច់ឆ្នាំ២០១៦។ | | | | | | | | | | | | | | | | | | |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល | ២០០៨ | ២០១៥ | | ការអនុវត្តចំណូលប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀង+/-ពី៥%) | | | | | | | | | | | | | | |
| ១១.១. អនុវត្តគោលនយោបាយចំណូលរយៈពេលមធ្យម និងយុទ្ធសាស្ត្រកៀរគរចំណូល | ២០១៤ | ២០១៨ | អគ្គ. គោលន/បាគយ ពន្ធដារ ឧស្សាហកម្ម ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ក្រសួង ស្ថាប័ន | ○ ប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល (កើនប្រចាំ ឆ្នាំ= កំណើនពិត ផសស+ អតិផរណា +៥%)<br>○ ការអនុវត្តយុទ្ធសាស្ត្រគៀងគរចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព (១) | ពេលវេលាត្រូវការ (ថ្ងៃ ខែ ឆ្នាំ) (២) ចាប់ផ្តើម | ពេលវេលាត្រូវការ (២) បញ្ចប់ | ក្រសួង ស្ថាប័ន/អង្គភាព (៣) | សូចនាករសមិទ្ធកម្មគន្លឹះ (៤) | ២០១៦ ត្រីមាស ១ | ២០១៦ ត្រីមាស ២ | ២០១៦ ត្រីមាស ៣ | ២០១៦ ត្រីមាស ៤ | ២០១៧ ត្រីមាស ១ | ២០១៧ ត្រីមាស ២ | ២០១៧ ត្រីមាស ៣ | ២០១៧ ត្រីមាស ៤ | ២០១៨ ត្រីមាស ១ | ២០១៨ ត្រីមាស ២ | ២០១៨ ត្រីមាស ៣ | ២០១៨ ត្រីមាស ៤ | ប្រភពហិរញ្ញប្បទាន (៦) ប្រភព | ប្រភពហិរញ្ញប្បទាន (៦) សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១.១.១. រៀបចំការត្រួតពិនិត្យ តាមដាននិង វាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល | កក្កដា ២០១៦ | មិថុនា ២០១៨ | នាយកដ្ឋានម៉ាក្រូ និង សារពើពន្ធ | ១. មានរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំឆមាស | | | ✔ | | | | ✔ | | | ✔ | | | PFM | ៥០,០០០ |
| | | | | ២. មានរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំឆ្នាំ | | | | | ✔ | | | | ✔ | | | | | |
| ១១.១.២ រៀបចំសិក្ខាសាលាបញ្ជាបចំណេះដឹង ដែលទទួលបានពីការបណ្តុះបណ្តាល និងដំណើរទស្សនកិច្ចនៅក្រៅប្រទេស ដល់មន្ត្រីផ្សេងទៀត | តុលា ២០១៦ | ធ្នូ ២០១៦ | នាយកដ្ឋានម៉ាក្រូ និង សារពើពន្ធ | ៣. សិក្ខាសាលាបញ្ជាបចំណេះដឹងដល់មន្ត្រីក្នុងអគ្គនាយកដ្ឋានត្រូវបានរៀបចំ | | | | ✔ | | | | | | | | | PFM | ៥,០០០ |



# ការអនុវត្ត និងសារៈសំខាន់ នៃប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ (CMS)

ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ គឺជាប្រព័ន្ធការងារដែលដំណើរការដោយបច្ចេកវិទ្យាព័ត៌មាន អនឡាញ ដែលត្រូវបានបង្កើតឡើងដោយអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅដំណាច់ឆ្នាំ២០១៥ និងត្រូវបានដាក់ឱ្យក្រសួង-ស្ថាប័នទាំងឡាយអនុវត្តតាមរយៈការបញ្ចូលទិន្នន័យ ផែនការចំណូល-ចំណាយប្រចាំខែ និងប្រចាំត្រីមាស។ ប្រព័ន្ធនេះ ដំណើរការដោយស្វ័យប្រវត្តិតាមបច្ចេកវិទ្យាព័ត៌មាន និងអាចចងក្រងបង្ហាញតួលេខនានាពាក់ព័ន្ធនឹងចំណូលនិងចំណាយ សម្រាប់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ ពោលគឺសាមីក្រសួង ស្ថាប័ននីមួយៗមានឈ្មោះនិងលេខសម្ងាត់ផ្ទាល់របស់ខ្លួន ដើម្បីចូលទៅពិនិត្យទិន្នន័យចំណូល-ចំណាយផ្ទាល់របស់ខ្លួន តែពុំអាចចូលទៅកាន់ទិន្នន័យនៃក្រសួង-ស្ថាប័នដទៃទៀតឡើយ ខុសពីអគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាម្ចាស់លើប្រព័ន្ធនេះទាំងមូល គឺមានបុព្វសិទ្ធិ ជាគណនេយ្យករសាធារណៈ អាចចូលពិនិត្យមើលតួលេខ ទិន្នន័យចំណូល ចំណាយរបស់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ដែលអនុវត្តប្រព័ន្ធនេះ។

ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងការពិនិត្យតាមដាន ទំហំនៃលំហូរសាច់ប្រាក់ របស់ក្រសួង-ស្ថាប័ននីមួយៗ ដែលជាមូលដ្ឋានដ៏មានសារៈសំខាន់សម្រាប់រៀបចំការព្យាករណ៍លំហូរសាច់ប្រាក់និងផែនការគ្រប់គ្រងសាច់ប្រាក់ ប្រកបដោយប្រសិទ្ធភាពនិងភាពទាន់ពេល។

យ៉ាងណាក៏ដោយ ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ គឺជាឧបករណ៍សាកល្បងមួយដោយឡែក ដែលមានគោលដៅបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការពាក់ព័ន្ធនៅតាមក្រសួង ស្ថាប័ន ក្នុងការប្រើប្រាស់ជាបណ្តើរៗនូវបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីត្រៀមខ្លួនបោះជំហានឆ្ពោះទៅកាន់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមបច្ចេកវិទ្យាព័ត៌មានវិទ្យា គឺ «ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» (Financial Management Information System-FMIS) នៅ ដំណាក់កាលខាងមុខ។

ក្នុងដំណើរការសាកល្បងនៃប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់នេះ អគ្គនាយកដ្ឋានរតនាគារជាតិ បានផ្តល់ការបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់មន្ត្រីរាជការនៃក្រសួង-ស្ថាប័ន ដែលចូលរួមអនុវត្តប្រព័ន្ធនេះ៕

# ការគ្រប់គ្រងហានិភ័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើដំណើរអស់រយៈពេលជាងមួយទសវត្សកន្លងទៅ នៅលើវិថីដ៏វែងឆ្ងាយមួយ ដែលពោរពេញទៅដោយឧបសគ្គនិងការលំបាកជាច្រើន ដែលបានរារាំងដល់ការសម្រេចជោគជ័យលើគោលដៅចុងក្រោយរបស់ខ្លួន គឺឧត្តមានុវត្តន៍និងស្តង់ដារអន្តរជាតិនៃការគ្រប់គ្រងប្រព័ន្ធថវិកា។

ដើម្បីជម្នះបញ្ហាប្រឈមទាំងឡាយ និងក្តាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងហានិភ័យ គឺជាកត្តាដ៏មានសារៈសំខាន់សម្រាប់ចូលរួមចំណែកធានាប្រសិទ្ធភាពនិងស័ក្តសិទ្ធភាពនៃកិច្ចដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## និយមន័យនៃហានិភ័យ

ហានិភ័យ គឺជាព្រឹត្តិការណ៍ដែលបង្កការគំរាមកំហែងដល់លទ្ធផល ឬសមិទ្ធកម្មរបស់កម្មវិធី ដែលបានគ្រោងទុក។ហានិភ័យមានលក្ខណៈមិនជាក់លាក់ ពុំទៀងទាត់ ពុំអាចលុបបំបាត់ ឬទប់ស្កាត់បានទាំងស្រុង ប៉ុន្តែអាចត្រូវបានកាត់បន្ថយឥទ្ធិពលតាមរយៈវិធានការបង្ការ ទប់ស្កាត់ ឬ បញ្ចៀសដោយប្រើប្រាស់អភិក្រមបុរេសកម្ម សកម្ម និងអន្តរសកម្ម។ ជាទូទៅ ប្រសិនបើហានិភ័យនោះកើតឡើង លទ្ធផល ឬសមិទ្ធកម្មដែលទទួលបាននឹងអាចខុសពីការរំពឹងទុក។

ហេតុនេះ ហានិភ័យចាំបាច់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដ៏ជាក់លាក់មួយ។ ក្នុងន័យនេះ ការគ្រប់គ្រងហានិភ័យសំដៅដល់ដំណើរការកំណត់ និងវិភាគហានិភ័យ ដើម្បីរៀបចំនិងដាក់ចេញនូវវិធានការបង្ការ ទប់ស្កាត់ កាត់បន្ថយអានុភាព ឬ បញ្ចៀសហានិភ័យប្រកបដោយប្រសិទ្ធភាព។

ចំពោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហានិភ័យត្រូវបានកំណត់ចេញពីបញ្ហាប្រឈមចម្បងៗដែលបានជួបប្រទះនៅដំណាក់កាលទី១ និងដំណាក់កាលទី២ និងបន្តជះឥទ្ធិពលអវិជ្ជមានដល់សមិទ្ធកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងជំហាន និងដំណាក់កាលបន្ទាប់។

## កម្រិតនៃហានិភ័យ

ហានិភ័យ ត្រូវបានធ្វើចំណាត់ថ្នាក់ ជា ៣ កម្រិត ដូចខាងក្រោម÷

**ក. កម្រិតខ្ពស់ ÷** សំដៅដល់ហានិភ័យទាំងឡាយណាដែលជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតអាចបញ្ឈប់ដំណើរការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ខ. កម្រិតមធ្យម ÷** សំដៅដល់ហានិភ័យទាំងឡាយណាដែលជះឥទ្ធិពលអវិជ្ជមានមធ្យម ដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជាការរាំងស្ទះ ដែលបង្កឱ្យមានភាពយឺតយ៉ាវខ្លាំង ឬពន្យារពេលយូរដល់ការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**គ. កម្រិតទាប ÷** សំដៅដល់ហានិភ័យទាំងឡាយណាដែលជះឥទ្ធិពលអវិជ្ជមានជាផលរំខាន ដល់ការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ហានិភ័យ និង សំណើវិធានការដោះស្រាយ

ហានិភ័យ ទាំង ៣ កម្រិត និងវិធានការដោះស្រាយ ត្រូវបានស្នើឡើង ដូចខាងក្រោម÷

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| ១ | **ភាពជាម្ចាស់/ភាពជាអ្នកដឹកនាំ**<br>• កង្វះឆន្ទៈ, ភាពជាម្ចាស់, ភាពជាអ្នកដឹកនាំ, ការទទួលខុសត្រូវ និងការផ្តល់អាទិភាពលើការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីកែទម្រង់ពាក់ព័ន្ធផ្សេងទៀត | ខ្ពស់ | • ក្រសួង- ស្ថាប័ន<br>• កសហវ<br>• អ. គ. ហ. | • ត្រូវបង្កើនឆន្ទៈ, ភាពជាម្ចាស់, ការទទួលខុសត្រូវ ព្រមទាំងពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រងដល់ថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ តាមរយៈការជំរុញនិងលើកទឹកចិត្តឱ្យមានការដាក់ចេញជាសកម្មភាពពាក់ព័ន្ធនៅក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៣ និងដំណាក់កាលបន្តបន្ទាប់ទៀត<br>• រៀបចំឱ្យមានកិច្ចប្រជុំជាប្រចាំរបស់ក្រុមការងារកែទម្រង់ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ដើម្បីពិនិត្យតាមដានលើវឌ្ឍនភាពកម្មវិធីកែទម្រង់<br>• បង្កើនការផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដល់កម្រិតថ្នាក់ដឹកនាំនយោបាយ, កម្រិតថ្នាក់ដឹកនាំបច្ចេកទេស និងកម្រិតជំនាញ តាមរយៈសិក្ខាសាលា សន្និសីទ និងបទឧទ្ទេសនាមពាក់ព័ន្ធនានា។ |
| ២ | **ធនធានមនុស្ស**<br>• ការប្រើប្រាស់ធនធានមនុស្សមិនចំគោលដៅនិងការផ្លាស់ប្តូរធនធានមនុស្សញឹកញាប់ក្នុងពេលអនុវត្តកម្មវិធីកែទម្រង់តាមដំណាក់កាលនីមួយៗ<br>• កង្វះធនធានមនុស្សសម្រាប់អនុវត្តកម្មវិធីកែទម្រង់នៅដំណាក់កាលនីមួយៗ<br>• មិនមានការកំណត់គោលដៅការងារច្បាស់លាស់សម្រាប់ក្រុមការងារកែទម្រង់ | ខ្ពស់ | • កសហវ<br>• ក្រសួង- ស្ថាប័ន<br>• អ. គ. ហ. | • ពិនិត្យមើលឡើងវិញនូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការបណ្តុះបណ្តាល និងកំណត់ពីតម្រូវការ ធនធានមនុស្សសម្រាប់ការងារកែទម្រង់ឱ្យបានច្បាស់លាស់ និងស្របតាមពេលវេលាជាក់លាក់<br>• រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ដំណាក់កាលទី៣និងដំណាក់កាលបន្តបន្ទាប់ ដែលរួមមានទាំងការបណ្តុះបណ្តាលជំនាញនៅក្នុង កសហវ និងក្នុងក្រសួង- ស្ថាប័នពាក់ព័ន្ធ<br>• រៀបចំកំណត់អាណត្តិនិងលក្ខខណ្ឌយោង (TOR) របស់ក្រុមការងារកែទម្រង់ឱ្យបានច្បាស់លាស់បន្ថែមទៀត។ |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
| --- | --- | --- | --- | --- |
| ៣ | **ការគ្រប់គ្រងផ្ទៃក្នុង**<br>• កង្វះប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តថវិកាកម្មវិធី<br>• តួនាទីនៃអង្គភាព/ ស្ថាប័នក្នុងការអនុវត្តការងារត្រួតពិនិត្យ មិនច្បាស់លាស់ ឬជាន់គ្នា | ខ្ពស់ | • កសហវ<br>• ក្រសួង- ស្ថាប័ន | • ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលមានស្រាប់ ព្រមទាំងរៀបចំនូវប្រព័ន្ធត្រួតពិនិត្យថ្មីដែលអាចឆ្លើយតបបានទៅនឹងបរិបថថ្មីនៃថវិកាកម្មវិធីប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់<br>• ត្រួតពិនិត្យឡើងវិញពីមុខងារនិងតួនាទីនៃអង្គភាពត្រួតពិនិត្យនិងវាយតម្លៃហើយកែសម្រួលដើម្បីបង្កើនភាពច្បាស់លាស់ និងបន្ថយការត្រួត ឬ ជាន់គ្នា។ |
| ៤ | **ប្រតិភូកម្មអំណាច**<br>• គោលការណ៍ណែនាំនៃការរៀបចំនិងអនុវត្តរបស់អង្គភាពថវិកា មិនទាន់បានគ្រប់ជ្រុងជ្រោយ<br>• កង្វះការផ្ទេរសិទ្ធិអំណាចដល់អង្គភាពថវិកាឱ្យបានពេញលេញ<br>• ប្រើប្រាស់សិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មមិនបានត្រឹមត្រូវ | ខ្ពស់ | • ក្រសួង- ស្ថាប័ន<br>• កសហវ | • បន្តកែលម្អគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តរបស់អង្គភាពថវិកាឱ្យបានច្បាស់លាស់ជាងមុន<br>• បន្តជំរុញការធ្វើប្រតិភូកម្មអំណាចទៅអង្គភាពថវិកាឱ្យបានច្រើនជាងមុនរហូតក្លាយជាអង្គភាពថវិកាពេញលេញ<br>• បន្តផ្សព្វផ្សាយអំពីសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា<br>• បន្តពង្រឹងនិងបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ។ |
| ៥ | **សមាហរណកម្មថវិកា**<br>• ការធ្វើសមាហរណកម្មថវិកា នៅមានកម្រិត<br>• កម្មវិធីវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល មិនទាន់អាចប្រើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP), ក្របខ័ណ្ឌថវិកាបីឆ្នាំ រំកិល និងថវិកាប្រចាំឆ្នាំបាន<br>• សមាហរណកម្មរវាងថវិកាវិនិយោគក្នុងស្រុក និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ នៅមានកម្រិត | ខ្ពស់ | • កសហវ<br>• ក្រសួង- ស្ថាប័ន | • ពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងការរៀបចំថវិកាកម្មវិធីដើម្បីធានាសមាហរណកម្មថវិកាពេញលេញ<br>• ពង្រឹងគុណភាពនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP), ក្របខ័ណ្ឌថវិកាបីឆ្នាំរំកិល និងថវិកាប្រចាំឆ្នាំ<br>• រៀបចំក្របខ័ណ្ឌវិនិយោគ (Investment Framework) សំដៅធ្វើសុខដុមនីយកម្មនៃកម្មវិធីវិនិយោគសាធាណៈ<br>• រៀបចំធ្វើសុខដុមនីយកម្មលើយន្តការនិងនីតិវិធីគ្រប់គ្រងគម្រោងវិនិយោគទាំងអស់ពីប្រភពហិរញ្ញ- ប្បទានវិនិយោគក្នុងស្រុក និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍<br>• បន្តវិភាជន៍ថវិកាវិនិយោគក្នុងស្រុកផ្ទាល់ទៅវិស័យអាទិភាពឱ្យកាន់តែច្រើន តាមដែលអាចធ្វើបាន។ |



| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
| --- | --- | --- | --- | --- |
| ៦ | **លទ្ធផលសម្រេចបាននៅដំណាក់កាលទី១ និងទី២ ដែលត្រូវបន្តអនុវត្តនៅដំណាក់កាលទី៣ និងដំណាក់កាលបន្តបន្ទាប់**<br>• ការអនុវត្តគោលនយោបាយចំណូលដែលនឹងពង្រីកមូលដ្ឋានប្រមូលចំណូល, ពង្រឹងការគ្រប់គ្រងចំណូល, និងបង្កើនសុក្រឹតភាពនៃការព្យាករណ៍ចំណូលមានវឌ្ឍនភាពយឺត<br>• ការអនុវត្តប្រព័ន្ធពតិមានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅមានកម្រិត ឬ ត្រូវការពេលវេលាច្រើនដែលប៉ះពាល់ដល់ការងារត្រួតពិនិត្យនិងគណនេយ្យភាពនៃការងារកែទម្រង់<br>• ការគាំទ្រហិរញ្ញវត្ថុសមាប្រ់អនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ នៅមិនទាន់មានភាពច្បាស់លាស់<br>• ក្រសួង- ស្ថាប័នមិនទាន់បានត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការអនុវត្តប្រព័ន្ធ FMIS។ | ខ្ពស់ | • រដ្ឋបាលប្រមូលចំណូល<br>• កសហវ<br>• ក្រសួង- ស្ថាប័ន | • បន្តជំរុញអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ សំដៅធានាឱ្យបានភាពជឿទុកចិត្តនៃថវិកា<br>• រៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនិងយន្តការដោះស្រាយបន្ថែមទៅលើយន្តការដែលមានស្រាប់ ជាពិសេសការអនុវត្តប្រព័ន្ធ FMIS<br>• បន្តពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ អំពីការគាំទ្រហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាពិសេសការពង្រីកការអនុវត្តដល់ក្រសួង ស្ថាប័នផ្សេងទៀត<br>• បន្តផ្សព្វផ្សាយអំពីការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS ដល់ក្រសួង- ស្ថាប័នដើម្បីមានចំណេះដឹងមូលដ្ឋានក្នុងការត្រៀមខ្លួនអនុវត្តប្រព័ន្ធ FMIS ឱ្យបានទាន់ពេលវេលា។ |
| ៧ | **ប្រព័ន្ធលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់**<br>• កង្វះការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង/ ឬ មិនមែនហិរញ្ញវត្ថុដល់ក្រុមការងារកែទម្រង់ អាចប៉ះពាល់ដល់ការអនុវត្តកម្មវិធីកែទម្រង់។ | មធ្យម | • កសហវ<br>• ក្រសួង- ស្ថាប័ន | • ពិនិត្យមើលឡើងវិញប្រព័ន្ធផ្តល់ការលើកទឹកចិត្ត រយៈពេលកន្លងមកនិងរៀបចំឱ្យមានប្រព័ន្ធផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង/ ឬ មិនមែនហិរញ្ញវត្ថុ ប្រកបដោយសមធមិ សង្គតិភាព និងតាមឆន្ទៈនៃការបំពេញការងាររបស់មន្ត្រីពាក់ព័ន្ធ។ |
| ៨ | **ការត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញ**<br>• កង្វះការត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់របស់ក្រសួង- ស្ថាប័នក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ អាចជះឥទ្ធិពលអវិជ្ជមានដល់ការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាលទី៣ និងដំណាក់កាលបន្តបន្ទាប់ទៀត។ | មធ្យម | • កសហវ<br>• ក្រសួង- ស្ថាប័ន | រៀបចំប្រជុំត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ជាប្រចាំ<br>• រៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍នៃ ការងារថវិកាកម្មវិធី ដោយកំណត់បញ្ហាប្រឈមឱ្យបានច្បាស់លាស់ព្រមទាំងរៀបចំយន្តការដោះស្រាយបញ្ហាប្រឈមទាំងនេះ ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពខ្ពស់<br>• រៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការរៀបចំថវិកាកម្មវិធី, ការអនុវត្តថវិកាកម្មវិធី និងការរៀបចំនិងការអនុវត្តរបស់អង្គភាពថវិកា<br>• បន្តកែលម្អគោលការណ៍ណែនាំពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។ |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| ៩ | **ការសម្របសម្រួល**<br>• ប្រសិទ្ធភាពសម្របសម្រួលនៃកម្មវិធី កែទម្រង់ទាំងបី (PFM, PAR, NCDD) នៅមានកម្រិត<br>• ខ្វះការសម្របសម្រួល ឬទំនាក់ទំនងជាប្រចាំរវាងអគ្គនាយកដ្ឋាន និងអគ្គនាយកដ្ឋាន របស់ កសហវ និង/ ឬ ក្រសួង-ស្ថាប័ន និងក្រសួង-ស្ថាប័ន<br>• ការប្រើប្រាសប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ទំនាក់ទំនងគ្នានៅមានកម្រិត | មធ្យម | • ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>• PFM, PAR, NCDD | • បង្កើនទំនាក់ទំនងសម្របសម្រួលជាប្រចាំនិងជំរុញការអនុវត្តសេចក្តីសម្រេចរួមស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥។ ក្នុងករណីចាំបាច់ត្រូវកែលម្អសេចក្តីសម្រេចរួមនេះ។<br>• រៀបចំនិងអនុវត្តផែនការសកម្មភាពរួម ដើម្បីដោះស្រាយបញ្ហាប្រឈមនៃកំណែទម្រង់ទាំងបី<br>• រៀបចំយន្តការកាត់បន្ថយ និង/ ឬដោះស្រាយបញ្ហាត្រួតគ្នានៃកំណែទម្រង់ទាំងបី (Cross Cutting Issues)<br>• ពង្រឹងទំនាក់ទំនងជាប្រចាំរវាងថ្នាក់ដឹកនាំនិងមន្ត្រីបង្គោលក្នុងអង្គភាព និង/ ឬ អន្តរក្រសួង-ស្ថាប័ន ក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>• ជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីពង្រឹងទំនាក់ទំនងរបស់មន្ត្រីបង្គោលពាក់ព័ន្ធ។ |
| ១០ | **រចនាសម្ព័ន្ធក្រសួង-ស្ថាប័ននិងកម្មវិធី**<br>• រចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នមិនឆ្លើយតបតាមរចនាសម្ព័ន្ធរបស់ថវិកាកម្មវិធី<br>• តួនាទីនិងភារកិច្ចមិនច្បាស់លាស់រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចប៉ះពាល់ដល់គណនេយ្យភាពនៃថវិកាកម្មវិធី | មធ្យម | • កសហវ<br>• ក្រសួង-ស្ថាប័ន | • ត្រួតពិនិត្យនិងកែលម្អរចនាសម្ព័ន្ធក្រសួង-ស្ថាប័ន ដើម្បីឆ្លើយតបនឹងរចនាសម្ព័ន្ធរបស់ថវិកាកម្មវិធី<br>• កំណត់បន្ទាត់គណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ, ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងការអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ត្រួតពិនិត្យនិងកែលម្អគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ១១ | **ហិរញ្ញប្បទានគាំទ្រ**<br>• កង្វះហិរញ្ញប្បទានគាំទ្រ អាចជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ | ទាប | • ដៃគូអភិវឌ្ឍន៍<br>• រាជរដ្ឋាភិបាល | • អនុវត្តឱ្យបាននូវក្របខ័ណ្ឌវាយតម្លៃសមិទ្ធកម្ម (Performance Assessment Framework) រវាងដៃគូអភិវឌ្ឍន៍ និង រាជរដ្ឋាភិបាល<br>• ធានាឱ្យបាននូវភាពទុកជឿទុកចិត្តនៃថវិកា តាមរយៈបន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមក្រោយៗទៀត ព្រមទាំងបន្តធ្វើវិចារណកម្មចំណាយឱ្យបានជាប្រចាំ។ |



| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| ១២ | **ការគាំទ្រផ្នែកនយោបាយ**<br>• កង្វះការគាំទ្រផ្នែកនយោបាយ | ទាប | • គ. ហ. ស.<br>• ក្រសួង-ស្ថាប័ន<br>• កសហវ | • បន្តនិរន្តភាពនៃការគាំទ្រផ្នែកនយោបាយពី គ. ហ. ស និងក្រុមការងារបច្ចេកទេសកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ |
| ១៣ | **ក្របខ័ណ្ឌពេលវេលាសម្រេចចក្ខុវិស័យឆ្នាំ២០២០**<br>• ក្របខ័ណ្ឌពេលវេលាខ្លី សម្រាប់ឈានទៅសម្រេចគោលដៅឆ្នាំ២០២០ នៃការកែទម្រង់ប្រព័ន្ធថវិកា<br>• ឧបករណ៍គាំទ្រមិនទាន់ដំណើរការពេញលេញ ឬនៅមានកង្វះចន្លោះ ដូចជាប្រព័ន្ធ FMIS, លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនិងគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងទៀត<br>• បទពិសោធន៍និងសមត្ថភាពនៅមានកម្រិត | ទាប | • កសហវ<br>• ក្រសួង-ស្ថាប័ន | • បង្កើនការតាមដានលើការគ្រប់គ្រងហានិភ័យពាក់ព័ន្ធ<br>• បន្តពង្រឹងការផ្សព្វផ្សាយពីការងារពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ និងអនុវត្តនូវសំណើវិធានការដោះស្រាយនានាលើហានិភ័យពាក់ព័ន្ធ ដែលអាចបង្កឱ្យមានភាពរាំងស្ទះដល់ការសម្រេចចក្ខុវិស័យវែងឆ្ងាយនៃកម្មវិធីកែទម្រង់តាមកាលកំណត់។ |

## ទី១

អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ÷ ត្រូវមានមនសិការវិជ្ជាជីវៈ និងប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ។

## ទី២

អនុវត្តការងារជាក្រុម÷ បំពេញការងារ ដើម្បីបម្រើឧត្តមប្រយោជន៍ នៃការពង្រឹងស្ថាប័ន និងយន្តការការងារ ដោយយោងលើស្មារតីនៃការគោរពឋានានុក្រមមុខងារ និងភារកិច្ចរៀងៗខ្លួន ព្រមទាំងស្មារតីសាមគ្គីភាព និងឯកភាពរឹងមាំ ទាំងផ្នែកទស្សនៈ គោលជំហរ និងសកម្មភាព។

# អភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទី៣

អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម÷ មិនបង្កើតបញ្ហា បង្ការ និងទប់ស្កាត់មិនឱ្យកើតមាន និងដោះស្រាយបញ្ហានៅតិចតួច។

## ទី៤

មិនត្រូវមើលរំលងកំហុសខ្លួនឯង÷ ទទួលកំហុស និងកែតម្រូវកំហុសខ្លួនឯង ដោយអនុលោមតាមអភិក្រមការងារ ៤យ៉ាង របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា គឺ «ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល»។

## អាសយដ្ឋានទំនាក់ទំនង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទៈ (៨៥៥) ២៣ ៤៣០ ៧៩១
ទូរសារៈ (៨៥៥) ២៣ ៤៣០ ៧៤៥
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm